**BMI0159**

## សម្ភាសន៍ជាមួយឈ្មោះ វ៉ាន់ ប៊ុនម៉ា ភេទស្រី អាយុ៥៥ឆ្នាំ
## និង ណៃ ផាន ភេទប្រុស
## មុខងារជំនាន់ខ្មែរក្រហម “ប្រជាជនធ្វើការនៅកងចល័ត ”
## រស់នៅភូមិស្រះកើត ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ
## ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១
## សម្ភាសន៍ដោយៈ ឆាយ ឈុនលី
## ០១:៤៥:៤៥
## ៤៥ទំព័រ

ឈុនលី : ខ្ញុំសុំសំភាសន៍មីង ហើយខ្ញុំសុំណែនាំម្តងទៀត ខ្ញុំឈ្មោះឈុនលី មកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹង ហើយដូចខ្ញុំបានជំរាបមីងអ៊ីចឹង ខ្ញុំចង់សរសេររឿងទាក់ទងនឹងអាងត្រពាំងថ្មដើម្បីឲ្យក្មេងជំនាន់ក្រោយបានដឹងបានរៀនអ៊ីចឹង ព្រោះឥឡូវវាជាកន្លែងទេសចរណ៍ផងអ៊ីចឹងចឹងកុំឲ្យថាបានតែទៅលេងតែអត់ដឹងថាប្រវត្តិពីមុនវាយ៉ាងម៉េច ។

ប៊ុនម៉ា : ប្រវត្តិនោះដឹងតែម៉ាសារីពួកខ្ញុំនេះឯងដែលបានទៅទីនោះណាស ។

ឈុនលី : អ៊ីចឹងថ្ងៃនេះទី១៧ ខែមិថុនា ។ អ៊ីចឹងខ្ញុំសុំថតរូបមីងដែរណាសមីងអត់អីទេហ្អីមីង?

ប៊ុនម៉ា : អត់អីទេ ។

ឈុនលី : ហើយនេះខ្ញុំថតសំលេងព្រោះខ្ញុំកត់អត់ទាន់ចឹងពេលទៅវិញខ្ញុំយកទៅស្តាប់ ។ អ៊ីចឹងដំបូងខ្ញុំសុំសួរឈ្មោះមីង មីងឈ្មោះអី?

ប៊ុនម៉ា : ឈ្មោះនាមត្រកូលដែរហ្អី?

ឈុនលី : ចា៎!

ប៊ុនម៉ា : ឈ្មោះ វ៉ាន់ ប៊ុនម៉ា ។

ឈុនលី : ភេទស្រី អាយុប៉ុន្មាន?

ប៊ុនម៉ា : អាយុ៥៥ ។

ឈុនលី : នៅភូមិ?

ប៊ុនម៉ា : ស្រះកើត ។

ឈុនលី : ស្រុកកំណើតនៅឯណាវិញមីង?

ប៊ុនម៉ា ៖ ស្រុកកំណើតមីងនៅនេះឯង ។

ឈុនលី ៖ បងប្អូនប៉ុន្មាននាក់មីង?

ប៊ុនម៉ា ៖ បងប្អូនប្រាំបួននាក់ ។

ឈុនលី ៖ ច្រើនណាស់ ។

ប៊ុនម៉ា ៖ ច្រើន ។

ឈុនលី ៖ ស្រីប៉ុន្មានប្រុសប៉ុន្មាន?

ប៊ុនម៉ា ៖ ស្រី៧ប្រុស២ ។

ឈុនលី ៖ មីងកូនទីប៉ុន្មាន?

ប៊ុនម៉ា ៖ ខ្ញុំកូនទីបី ។

ឈុនលី ៖ រៀនបានថ្នាក់ទីប៉ុន្មាន?

ប៊ុនម៉ា ៖ រៀនថ្នាក់ទី១០ពីដើមមិញ ថ្នាក់ទី១០ពីដើមស្មើថ្នាក់ទី២សព្វថ្ងៃ ។

ឈុនលី ៖ ហើយកាលពីដើមដូចជាមុនខ្មែរក្រហមនៅសម័យ លន់ នល់ មីងធ្វើអី?

ប៊ុនម៉ា ៖ អត់បានធ្វើអីទេ ឃ្វាលគោ ។

ឈុនលី ៖ នៅផ្ទះធម្មតា?

ប៊ុនម៉ា ៖ នៅផ្ទះធម្មតា ទៅរៀនផង ឃ្វាលគោផងនេះឯង ។ ម៉ែពុកគាត់អត់មានកូនប្រុស ។

ឈុនលី ៖ រៀនសាលាណាដែរ?

ប៊ុនម៉ា ៖ រៀនសាលានេះឯង ស្រះលិច រៀននៅវត្តពីដើមមិញរៀនសាលាវត្ត ។

ឈុនលី ៖ កាលខ្ទង់៧៣ ៧៤អីអាយុប៉ុន្មានហើយ?

ប៊ុនម៉ា ៖ កាល៧៣ ៧៤អាយុប៉ុន្មានហើយឪវា?

ឈុនលី ៖ អាយុ២០ហើយហ្អីបើឥឡូវ៥៥?

ប៊ុនម៉ា ៖ ២០ហើយ គិតមើលទៅមើលមិនដែលគិតផងអារឿងចឹងៗ ។

ឈុនលី ៖ អីចឹងកាលនោះ២០ហើយហ្នឹង តែអត់ទាន់មានគ្រួសារទេ?

ប៊ុនម៉ា ៖ ទេ ដែល២០នោះមានហើយ ។

ឈុនលី ៖ អីចឹងមីងបានគ្រួសារឆ្នាំណា?

ប៊ុនម៉ា ៖ ៧៦ ចុង៧៦ចឹងហើយហ្អីឪវា ហួស!៧៧ ។

ឈុនលី ៖ ចុះពេលខ្មែរក្រហមចូលមកហ្នឹងឆ្នាំណា៧៥ ឬ៧៤នៅនេះ?

ប៊ុនម៉ា ៖ ៧៣ហ្អីឪវា?

ឈុនលី ៖ ខ្មែរក្រហមចូលភ្នំពេញឆ្នាំ៧៥ណាសពូ?

ផាន ៖ នៅភូមិនេះវាមកតាំងពី៧៣បាញ់គ្នាព្រោងព្រាតហែលទឹកហែលអី ។

ឈុនលី ៖ អ្នកណាគេហែលទឹក?

ផាន ៖ ពួកអ្នកភូមិនេះឯងឆ្លងទឹកទៅនៅស្រមោចនៅអី ។

ឈុនលី ៖ ឆ្នាំ៧៣ចូលមកដល់ណា?

ប៊ុនម៉ា ៖ ឆ្នាំ៧៣ ចូលមកដល់ភូមិយើងហើយ ។

ផាន ៖ ឆ្នាំ៧៣ហ្នឹងកំពង់តែប្រទាញប្រទង់គ្នា សម័យនោះនៅសម័យសង្គ្រាមដល់៧៥បានវាចូលកាន់អំណាច ។

ឈុនលី ៖ ចូលមកដល់ប្រទាញប្រទង់ចឹងមីងដឹងទេ?

ប៊ុនម៉ា ៖ ដឹងប្រទាញប្រទង់ដឹង ។

ឈុនលី ៖ គេប្រទាញប្រទង់បាញ់គ្នានៅឯណាទៅ?

ប៊ុនម៉ា ៖ តំបន់បាញ់គ្នានៅដូនប្រែងនេះឯង ដូនប្រែងរត់មកនេះឯង ។

ផាន ៖ ទេ អាហ្នឹងក្រោយទេ ។ កាល៧៣ទាហាន លន់ នល់ វានៅនេះដល់ពេលបាញ់គ្នាទាហានមកនៅនេះវាឡើងមកពីក្រោយអ្នកស្រុកនេះរត់ទៅណាស អានេះសម័យសង្គ្រាមដូចយើងសម័យ លន់ នល់ ហ្នឹងណាសហើយដល់អាសម័យ៧៥បានគេគ្រប់គ្រងអំណាចនេះ...

ប៊ុនម៉ា ៖ ចុះសម័យដែលតាសឺន រត់ទៅនេះ?

ផាន ៖ អានោះ៧៩ហើយអានេះចល័ត កាលនោះនៅកងចល័តទៅនៅអាងត្រពាំងថ្មណាស៧៥ទៅធ្វើកងចល័ត ។

ឈុនលី ៖ ៧៥ទៅធ្វើម៉េង?

ផាន ៖ បាទ!៧៥ដឹងតែប្រមូលអស់ហើយ ខ្ញុំចេញពីស្រុកមក៧៥ គេបញ្ជូនមកហើយ ។

ឈុនលី ៖ ពូបានទៅប្រពាំងថ្មដែរ?

ផាន ៖ អត់ទេ នេះបានទំនប់កំបោរនេះ បាត់ប្អូនមួយកាលសម័យបីឆ្នាំ ។

ឈុនលី ៖ ចុះបើមីងអ្នកស្រុកនេះម៉េង?

ប៊ុនម៉ា ៖ ខ្ញុំអ្នកស្រុកនេះឯង ។

ឈុនលី ៖ ហើយបានទៅត្រពាំងថ្មទៀត?

ប៊ុនម៉ា ៖ ទៅត្រពាំងថ្មហើយទៅដល់ទំនប់រំបេកមុនគេ មុនត្រពាំងថ្ម ។

ឈុនលី ៖ ចុះពេលគេប្រទាញប្រទង់ហ្នឹងមិនមានរត់ទៅណាដែរអត់?

ប៊ុនម៉ា ៖ អត់មានរត់ទៅណាទេ ។

ឈុនលី ៖ នៅស្រុកភូមិហ្នឹង?

ប៊ុនម៉ា ៖ ហ្នឹងឯងនៅភូមិនេះឯង តែគ្រាន់តែអ្នកនៅដូនប្រែងរត់មកនៅដីយើងនេះណាស នៅស្រែះ ដល់គ្នាស្រកទឹកទៅគ្នាខ្លាចមិនដឹងទៅនៅឯណា អ្នកចែកអង្ករចែកអីមកនៅនេះ ។

ឈុនលី ៖ ចុះដល់ពេល៧៥ពេលខ្មែរក្រហមចូលមកដល់?

ប៊ុនម៉ា ៖ ពេលខ្មែរក្រហមចូលមក...

ឈុនលី ៖ យ៉ាងម៉េចទៅក្នុងភូមិ?

ប៊ុនម៉ា ៖ វាភ្លេចអស់ហើយ ។

ឈុនលី ៖ ចូលមកគេមានថាម៉េច គេគំរាមអីដែរអត់?

ប៊ុនម៉ា ៖ ចូលមកគេធ្វើដូចចោរចេះឯង គេដេញឲ្យយើងចេញ លួចគោលួចអីសព្វមុខ ។

ឈុនលី ៖ គេដេញឲ្យយើងចេញហើយថាម៉េច?

ប៊ុនម៉ា ៖ គេដេញឲ្យយើងគេចខ្លួន ឲ្យយើងគេចខ្លួនទៅលើៗឯណោះ ។

ឈុនលី ៖ ទៅខាងណាវិញ?

ប៊ុនម៉ា ៖ ទៅអីណាទេឪវា ទៅកូនខ្វែង តែអ្នកទៅក៏ទៅ ពួកខ្ញុំអត់បានទៅទេ ។

ឈុនលី ៖ ម៉េចបានឲ្យទៅកូនខ្វែងចឹង?

ប៊ុនម៉ា ៖ បើគេដេញឲ្យយើងទៅធ្វើទ័ពជាមួយវាណាស ច្បាំងជាមួយពួកទាហានខ្មែរយើងជាមួយយួនជាមួយអីណាស ។

ឈុនលី ៖ ជាមួយពួក លន់ នល់?

ប៊ុនម៉ា ៖ ហ្នឹងឯងជាមួយពួក លន់ នល់ ដូចថាគេគេណាសគេកៀរយើងឲ្យឡើងទៅធ្វើកងទ័ពណាស ។

ឈុនលី ៖ ឲ្យទៅដល់មីងអត់ទៅ ទៅណាវិញ?

ប៊ុនម៉ា ៖ នៅនេះឯង ។

ឈុនលី ៖ អត់ទៅចឹងគេអត់ថាអីដែរ?

ប៊ុនម៉ា ៖ អត់ទេគេអត់ថាអីទេ គេយកអ្នកស្ម័គ្រចិត្តណាស ។

ឈុនលី ៖ ចុះមីងមានជម្លៀសចេញពីនេះដែរអត់?

ផាន ៖ គាត់នេះនិយាយស្តាប់គ្នាអត់បានទេ នាងនិយាយ៧៩ភូមិនេះគេមិនបានជម្លៀសយើងចេញទេ ។

ប៊ុនម៉ា ៖ ភូមិនេះគេអត់ជម្លៀសទេ ។

ផាន ៖ គេជម្លៀសប្រជាជនពីភ្នំពេញមកដាក់នៅនេះមានចិនមានយួនមកនៅតាមជើងភ្នំជើងអីណាស ។ អ្នកមូលដ្ឋានឲ្យតែយុវជននារីគេប្រមូលទៅធ្វើកងចល័តទាំងអស់លើកទំនប់ ។ នៅក្នុងភូមិនេះគេឲ្យយើងទៅប្រពាំងថ្ម ហើយយើងអ្នកមកពីភ្នំពេញនេះគេឲ្យទៅលើកទំនប់នេះ ពីនេះទៅរន្ទះបាញ់ ហើយលើកពីនេះទៅព្រះនេត្រព្រះដែរ ។ យុវជននារីគឺអត់បាននៅក្នុងភូមិទេ ទៅគាស់គល់គាស់អីទៅណាស ដូចថាយើងឈឺអីចឹងគេឲ្យត្រលប់មកវិញតែអត់ឲ្យនៅភូមិទេ ឲ្យទៅនៅគាស់គល់នៅកងពលសព្វថ្ងៃនេះ ។

ប៊ុនម៉ា ៖ នៅតាមក្រុមណាស យុវជននារី ។

ឈុនលី ៖ អីចឹងដូចពូអ្នកចំណូលថ្មីពូមកពីណា?

ប៊ុនម៉ា ៖ ខ្ញុំមកពីម្តុំខាងលិចភ្នំពេញនៅទួលលាប បែកចានយើងចេញពីភ្នំពេញទៅលិច ។

ឈុនលី ៖ គេដឹកឡានមក?

ផាន ៖ បាទ! គេដឹកឡានមក ចេញមកៗតាមភ្នំត្នោតពងយើងមកខាងលិចយើងចេញពីថ្នល់ទទឹងមកឡើងមកឧត្តុងហ្នឹង...ឡើងមកពោធិ៍សាត់ឡើងមកពោធិ៍សាត់ហើយបានគេយកមកដាក់នៅស្វាយហើយបានគេបែងចែក ។ អ្នកមានគ្រួសារទៅតាមភូមិទៅ ខ្ញុំអត់មានគ្រួសារបងប្អូនខ្ញុំគេឲ្យមកចល័ត ។ មកចល័តគេឲ្យលើកទំនប់កំបោរនេះមាដៃម៉ាម៉ែត្រគីប ពីរដៃពីម៉ែត្រគីបរហូតដល់ប្រាំម៉ែត្រគីប នៅពេលនោះអត់មានអ្នកណាទេ ទាំងអស់គ្នាដឹកតែទឹកបបរ បាយអត់បានទេ ។ បើយើងមិនធ្វើបើយើងថាងងឹតមាន់ទាល់តែមកទាំងងងឹតមាន់ហើយបើយើងថាអត់ទៅទេ ដឹងតែទៅហើយគេយកទៅវ៉ៃចោល ។

ឈុនលី ៖ មានដែរ?

ផាន ៖ បាទ ។

ឈុនលី ៖ ពូដែលឃើញដែរ?

ផាន ៖ បាទ នៅកំបោរនេះខ្ញុំឃើញផ្ទាល់ខ្លួនខ្ញុំហើយ បើងងឹតមាន់ដេកម៉ាក្រុមជាមួយខ្ញុំទៅ គេឲ្យទៅធ្វើការ ។ មេក្រុមងងឹតមាន់វាអត់ជឿទេណាស អីចឹងវាថាយកទៅរៀនសូត្រ ។ រៀនសូត្រអត់មានទេឯណាឆ្ងាយទេ ព្រៃនាមយើងខាងចុះពីទំនប់នេះទៅក្រោមទៅសព្វថ្ងៃគេធ្វើស្រែអស់ហើយដឹងតែតាមគុម្ពស្រូវហ្នឹងហើយ ឆាប់ចោលកប់តាមគុម្ព

ស្រូវ ។ បងប្អូនមកពីនោះមកច្រើនដែរគ្នីគ្នាមកពីនោះបាត់ ឲ្យតែយើងថាឈឺគឺយកមក ដេកពេទ្យបាត់រហូតដល់ពេលចប់ហើយ យើងលើកទំនប់ចប់ហើយនេះខ្ញុំនឹកទៅ ខ្ញុំសព្វថ្ងៃ គ្រូដែរតែប្រាប់កូនក្មេងទៅវាអត់ស្គាប់ តែដល់យើងជួបប្រទះខ្លួនឯងទៅនឹកឃើញវាពិបាក ។ ខ្ញុំ គេបញ្ជូនពីនោះមកដោយសារថាខ្ញុំនេះបងប្អូនគេអត់បែកគ្នាអស់ទៅគេកៀ អស់ទៅតែខ្ញុំអត់ទៅ ។ ដល់ពេលចប់នេះនេះគេចោទថាពួកសក្តិភូមិ ពួកសម័យលន់ នល់ ចឹងត្រូវបញ្ជូនខ្ញុំឲ្យមកនៅនេះដល់តែមកគេថាឲ្យនៅម៉ារហៈសិន តែម៉ាយៈហ្នឹងមកដល់ សព្វថ្ងៃ ។ ដល់ប្អូនស្រីមួយតាមខ្ញុំថា នឹកឃើញថាមកហ្នឹងច្បាស់ជាងាប់ហើយមិនរស់ទេ ដល់មកដល់ប្អូនសុំមកថារស់ទេ ។ ដល់តែមកប្អូនសុំមកខ្ញុំថាមិនបាច់ទេឲ្យខ្ញុំទៅតែឯង ។ ដល់ក្រោយមកទៀតបងខ្ញុំគាត់ធ្វើមេឃុំនៅ...ខាងស្រុកអង្គស្នួលតែឥឡូវគាត់ស្លាប់ហើយ យកប្អូនមកនៅនេះភ្នំតាផ្ដេយើងហ្នឹងណាស ដល់ភ្នំតាផ្ដេ ដល់មកនៅតាផ្ដេ ប្អូនខ្ញុំបើនៅ ប្រហែលហាជាងអីដែរហើយ តែហាតូចទេ នាងនោះអាណិតបងរត់ទៅវិញដល់បងនោះ អត់មានអីស៊ីគេតាមទៅចាប់ ហើយអ្នកនោះនៅនឹងភូមិខ្ញុំដែរគេហៅភូមិត្រពាំងអារក្ស ឃុំអាឡោកសព្វថ្ងៃគេកាត់ចូលរាជធានីហើយ ។ ដល់ពេលចប់មកទៀតខ្ញុំទៅ ខ្ញុំទៅខ្ញុំសួរ ថាចុះប្អូនខ្ញុំហ្នឹង បងប្រុសខ្ញុំគាត់សួរថា មីប្អូនខ្ញុំនោះវានៅចល័ត នៅចល័តគេតាមចាប់ នៅកង ទៅតាមចាប់ទៀតបាត់រហូត ។ យាយប៉ិហ្នឹងនៅដល់សព្វថ្ងៃ ទៅសួរថាកាល នោះប្អូនខ្ញុំយកទៅណាដែរ? គេថាមិនដឹងធ្វើម៉េចទេនៅក្រោមមេឃតែងតែត្រូវទឹក ភ្លៀងហើយ បានខ្ញុំថាចុះកាលពីដើមដែលខ្ញុំនៅសម័យ លន់ នល់ អ្នកណាួយដែលគេចផុត បើយើងមិនធ្វើទាហានយើងគេចទៅណាមិនរួច មានតែគេចាប់ ហើយខ្ញុំគេចាប់ទៅ រៀននៅក្បាលថ្នល់ម៉ាខែកន្លះ ហើយបានគេចទៅព្រៃសរនោះបីខែកបន្លះ ។ ទាហានហ្នឹង នៅតែពីរនាក់ពួកម៉ាក ភ្នំពេញសព្វថ្ងៃទើបតែជួនគ្នាទើបតែអំបាញ់មិញ ។បាញ់បាក់ទ័ព ទៅរត់ទៅអ្នកលឿងទៅទៅកៀកករគ្នាតែពីរនាក់ដល់ថ្ងៃមួយនោះទៅការក្លួយនោះជួប ជួបក៏រៀបរាប់ថាក្នុងម៉ាក្នុង...ងាប់អស់រលីងនោញធ្វើម៉េចខ្លះ? បានគេថាប្អូនបងឯងនេះខ្ញុំ បានតែចាប់ទេឲ្យទៅប្រធានវរៈហើយមិនដឹងប្រធានវរៈយកទៅណាទៀតទេ ។

ប្អូនស្រីខ្ញុំនោះខ្ញុំអាណិត អួលដើមករអាណិតប្អូនកំព្រាតាំងពីតូចអាយុដប់ឆ្នាណ ហើយប្អូនកាលនោះអាយុដប់ឆ្នាំម្ដាយខ្ញុំគាត់ស្លាប់នៅតែខ្ញុំពុកខ្ញុំ ឆ្អែត...(យំ) សព្វថ្ងៃនឹក ឃើញថាបើខ្ញុំទៅសឹងតែមិនចង់មើលមុខ ។

ឈុនលី : អ្នកហ្នឹងនៅឯណាពូ?

ផាន ៖ សព្វថ្ងៃនៅគេហៅត្រពាំងអារក្ស ឃុំអាឡោក ស្រុកអង្គស្នួលសព្វថ្ងៃកាត់ចូលរាជធានី ស្អីតាណាទេខ្ញុំភ្លេចបាត់ហើយ មានអីស្រុកកំណើតនៅជាមួយខ្ញុំហ្នឹងគ្រាន់តែថាគេបានធ្វើជាប្រធាននារីណាស ។

ឈុនលី ៖ អីចឹងកាលដែលចាប់ប្អូនពូហ្នឹងនៅឯណា នៅនេះឬនៅនោះ?

ផាន ៖ ចាប់នៅភ្នំតាផ្ដេរ ។

ឈុនលី ៖ អីចឹងគាត់ជំលៀសមកពីនោះជាមួយពូដែរ?

ផាន ៖ អត់ទេ មុនដំបូងគេជម្លៀសខ្ញុំទាំងប្រធានភូមិទាំងប្រធានសហករណ៍ ប្រធាមឈ្មួបប្រធាន អីហ្នឹងណាសគេថា ឥឡូវមិត្តឯងត្រូវទៅបាត់ដំបង ខ្ញុំថាចចុះខ្ញុំទៅធ្វើអី? គេថាមិត្តឯងនេះជាប់កំអែលចក្រព័ទ្ធ មិត្តឯងត្រូវទៅលត់ដំសិន ដល់ប្អូនខ្ញុំនោះគេសុំមក ប្អូនៗខ្ញុំគេកៀអស់ហើយ ហើយបងៗក៏គេកៀទៅ ហើយបងស្រីខ្ញុំមួយបែកគ្នាមកនៅឲ្យឧត្ដមានជ័យសព្វទើបត្រលប់មកវិញ ខ្ញុំនៅពីរនាក់ប្អូនហើយនឹងម្ដាយមីង ដល់អីចឹងទៅប្អូននោះសុំទៅថា បងអឺយខ្ញុំទៅដែរ! ខ្ញុំនឹកឃើញថាបើគេវៃខ្ញុំ ប្អូនខ្ញុំនៅឈរមើល តើប្អូនខ្ញុំស្លុតយ៉ាំងណា ហើយបើគេវៃប្អូនខ្ញុំតើខ្ញុំហ្នឹងស្លុតយ៉ាំងណា ។ ហើយខ្ញុំប្រាប់ថាអូនឯងកុំទៅអីនៅជាមួយម្ដាយមីង ហើយម្ដាយមីងហ្នឹងប្រពន្ធចុងឪពុកខ្ញុំហ្នឹងគាត់ថា “ខ្ញុំសុំធានាកូនខ្ញុំ” សព្វថ្ងៃវានៅវាឈ្មោះអាឆុំ នៅស្រុកត្រពាំងអារក្ស នៅត្រពាំងវែងវាសួរមីងខ្ញុំថា “មីងឯងហ៊ានសំលាប់ខ្លួនឯងទេ” ហើយបានខ្ញុំសួរទៅវិញថា “មើលមិត្តឯងសួរមីងខ្ញុំថា ហ៊ានសំលាប់ខ្លួនឯងហ្នឹងសួរចង់បានន័យថាម៉េច?” វាថាបើខ្ញុំធ្វើខុសថ្ងៃណា តើម្ដាយចុងខ្ញុំហ៊ានសំលាប់ខ្ញុំដែរអត់? បានខ្ញុំនឹកឃើញថា ឥឡូវមីងឯងមិនបាច់គិតពីខ្ញុំទេ មីងឯងមើល តែប្អូនខ្ញុំទៅបានហើយ ។ ចុះបើខ្ញុំកំពុងតែកសាងខ្លួនឲ្យល្អ ហើយគេនៅតែតាមចាប់កំហុសខ្ញុំ ថ្ងៃណាមួយខ្ញុំងាប់អត់អំពើក៏មាន អីចឹងមីងឯងមិនបាច់មើលផ្លូវខ្ញុំទេ មីងឯងគាត់ថាខ្ញុំងាប់មួយទៅចុះ ។ ខ្ញុំក៏ចេញមក ដល់ចេញមកខ្ញុំក៏ឡើងមកពោធិ៍សាត់ ក្រោយមកទៀតប្អូនខ្ញុំហើយម្ដាយមីងខ្ញុំ បងខ្ញុំ សព្វថ្ងៃខ្ញុំគាត់ស្លាប់ហើយគាត់នាំគ្នារត់ពីដីរំដោះគេហ្នឹងមកវិញ មកនៅភូមិហើយដល់គេដឹងថាបងខ្ញុំនេះរត់ពីដីរមដោះមក គេឲ្យគាត់ទៅនៅភ្នំតាផ្ដេរ អានោះបានម្ដាយមីងខ្ញុំគាត់មកទាំងអស់គ្នាបងខ្ញុំទាំងម្ដាយខ្ញុំទាំងប្អូនខ្ញុំ ។ ដល់មកដល់ភ្នំតាផ្ដេរគេថាខ្ញុំនេះជាប់កំអែលចាស់ចក្រព័ទ្ធ ហើយបងខ្ញុំរត់ពីដីគេនោះមករកចូលខ្មាំងបានតែម្ដាយចុងខ្ញុំមួយទេដែលគាត់នៅដីរំដោះ ពួកកូនគាត់នោះធ្វើទ័ពហើយដល់លទ្ធផលចុងក្រោយគាត់ស្លាប់នៅភ្នំតាផ្ដេរដូចគ្នាម្ដាយចុងខ្ញុំហ្នឹងហើយនឹងបាត់

ប្អូនខ្ញុំ ។ ដល់ពេលបងប្រុសខ្ញុំគាត់ត្រលប់ទៅវិញគាត់សួរថាដោយសារម្តាយចុងខ្ញុំហ្នឹង គាត់តាមរកខ្ញុំ បេះតែសួររកខ្ញុំច្រើនពេកទៅ គេថាគាត់ចង់រត់ចឹងទៅគេចាប់គាត់យកទៅ វ៉ៃចោលនៅភ្នំតាផ្តេរ ។ ខ្ញុំឲ្យបងខ្ញុំស្រាវជ្រាវរកគាស់ខ្មោចទៀត តែសព្វថ្ងៃបងខ្ញុំគាត់ស្លាប់អស់ហើយនៅសល់តែ ប្រពន្ធគាត់ ។

ឈុនលី : បងប្រុសស្លាប់ឆ្នាំណាពូ?

ផាន : បងប្រុសគាត់ស្លាប់ដោយរោគខ្លួនឯងទេ ប្រហែលពីរឆ្នាំមុនស្លាប់នៅភូមិបើប្អូនស្រីខ្ញុំបាត់តាំងពីនៅតាផ្តេរ ។

ឈុនលី : តាផ្តេរ នៅឯណាពូ?

ផាន : អាហ្នឹងនៅគាស់ក្រឡ ស្រុកគាស់ក្រល ។

ឈុនលី : ហ្អស!នៅស្រុកគាស់ក្រឡ?

ផាន : បាទ!បងស្រីខ្ញុំបេះតែឲ្យខ្ញុំផ្ញើពាក្យដាក់ទៅក្នុងកម្មវិធីមិនមិនសុបិន្តណាស បើបងខ្ញុំនេះមិនដឹងផងមិនដឹងគេចាប់ទៅណាទៅណើមិនដឹងជាងាប់ឬជារស់យ៉ាងណា ហើយបងខ្ញុំក៏គាត់ថាងាប់ហើយ ព្រោះពេលចាប់ទៅក្មួយបំផងអីផង ប្រធានចល័តគេនោះស្រី ។

ឈុនលី : អ៊ីចឹងបងប្អូនពូទាំងអស់បីនាក់?

ផាន : ប្រាំ ។

ឈុនលី : មានបងស្រី?

ផាន : មាន បងប្រុសបីស្រីពីរដែលបាត់ហ្នឹងបាត់ប្អូនស្រី ។

ឈុនលី : ដែលបាត់ហ្នឹងបាត់ប្អូនស្រី?

ផាន : បាទ បាត់ប្អូនពៅគេ ។

ឈុនលី : ចុះបងៗផ្សេងទៀត?

ផាន : បាទ!

ឈុនលី : ចុះបងមួយទៀត?

ផាន : បងប្រុសសព្វថ្ងៃមេភូមិនៅត្រពាំងអារក្ស ហើយបងស្រីមួយទៀតទៅនៅភូមិវិញហើយ ។

ឈុនលី : ត្រពាំងអារក្សនៅឯណាទៅ?

ផាន ៖ ត្រពាំងអារក្សនៅខាងលិចទួលលាបយើងចុះពីទួលលាប យើងចុះពីបែកចានទៅអាផ្លូវមួយទៅប្រសិទ្ធិណាស ។

ឈុនលី ៖ ហៅស្រុកអីគេអាហ្នឹង

ផាន ៖ គេហៅស្រុកអង្គស្នួល ។

ឈុនលី ៖ នៅភូមិជាមួយម្នាក់ស្រីដែលពូថាចាប់ប្អូនពូហ្នឹងហ្អី?

ផាន ៖ បាទ!

ឈុនលី ៖ ហើយឈ្មោះឆុំ ហ្នឹងហួស?

ផាន ៖ អាឆុំ ហ្នឹងប្រុស ។

ឈុនលី ៖ ហើយនៅក្នុងភូមិហ្នឹងដែរ?

ផាន ៖ បាទ!ស្រីនោះក៏នៅក្នុងភូមិហ្នឹងដែរ បងប្អូនសែស្រឡាយខាងគេនោះខាង ឆុំ ហ្នឹងដែរ ។

ឈុនលី ៖ ឆុំ ហើយស្រីហ្នឹងបងប្អូនគ្នា?

ផាន ៖ បាទ!

ឈុនលី ៖ ស្រីហ្នឹងឈ្មោះអី?

ផាន ៖ ខ្ញុំអត់ស្គាល់ឈ្មោះ ខ្ញុំភ្លេចឈ្មោះគាត់ ធំជាងខ្ញុំនេះដែរ ហើយមកដល់សព្វថ្ងៃគាត់ចាស់ខ្ញុំមិនស្គាល់គាត់ទេ ។

ឈុនលី ៖ ពូទៅសួរនាំគាត់សួរពីអន្លង់?

ផាន ៖ សួរពេលខ្ញុំចាប់ផ្តើមទៅនោះដំបូងបង្អស់ ។

ឈុនលី ៖ ឆ្នាំណា?

ផាន ៖ ឆ្នាំប្រហែល៨២ ។

ឈុនលី ៖ ទៅលេងហ្អី?

ផាន ៖ បាទ ទៅលេង ។

ប៊ុនម៉ា ៖ កាលទៅគេដាក់គុកគាត់ម៉ាខែ ។

ឈុនលី ៖ ម៉េចចឹង?

ផាន ៖ គេចោទខ្ញុំស៊្អីអីណា!

ឈុនលី ៖ ចឹងទៅហ្នឹងទៅជាមួយអ្នកណាខ្លះពូ?

ផាន ៖ ខ្ញុំទៅតែម្នាក់ឯង ។

ឈុនលី ៖ ទៅហ្នឹងនាមយ៉ាងម៉េចទៅរក?

ផាន ៖ ដើរទៅរកហើយខ្ញុំ បងខ្ញុំដែលពុំដឹងណឹងថាគាត់មកហ្នឹង បាត់បងស្រីនោះនាំគ្នាទៅសួរគាត់ ក្រែងលគាត់ត្រលប់មកស្រុកវិញ ។ ដល់ក្រោយមកទៀតគាត់ចេញពីខេត្តមានជ័យបាន គាត់ទៅ វាអាហ្នឹងយើងកំពុងតែខឹងរៀនខ្លួនហើយ សូម្បីតែបងប្អូនខ្ញុំនៅនោះ អាមួយនោះដេញបាញ់ណាស អាប្រធានឈ្លបនោះដេញបាញ់តែអត់ហ៊ាន អត់ហ៊ាននៅភូមិ ។

ឈុនលី ៖ អ្នកណាគេដេញបាញ់?

ផាន ៖ ពួកអ្នកភូមិហ្នឹងណាស ។

ឈុនលី ៖ ឈ្លបហ្នឹងឈ្មោះអី?

ផាន ៖ ឈ្មោះអាធន នៅត្រពាំងអារក្ស ។

ឈុនលី ៖ មេបស់ ឆ្នំ ហ្នឹងទៀត?

ផាន ៖ ទេ អាឆ្នំ ហ្នឹងគេមេភូមិ បានមេភូមិហើយមានឈ្លបមួយទៀត ។

ឈុនលី ៖ ក្រោម ឆ្នំ ហ្នឹងទៀត?

ផាន ៖ បាទ!ឈ្លបហ្នឹងខ្ញុំវាពិបាក ។

ឈុនលី ៖ ឥឡូវសព្វថ្ងៃនៅរស់ទៀត?

ផាន ៖ បាទ នៅរស់ ។

ឈុនលី ៖ ចឹងទាំង ឆ្នំ ទាំង ឈ្លបហ្នឹងរស់នៅភូមិជាមួយគ្នា?

ផាន ៖ បាទ!នៅជាមួយគ្នា ។

ឈុនលី ៖ ចឹងពេលពូទៅដល់ធ្វើម៉េចទៅ?

ផាន ៖ ទៅដល់មានអី សព្វថ្ងៃខ្ញុំអត់និយាយរកផង ខ្ញុំនឹកឃើញវា ។

ឈុនលី ៖ ចឹងអាកាលទៅដល់ឆ្នាំ៨២ហ្នឹង?

ផាន ៖ បាទ!ទៅដល់ខ្ញុំទៅហៅ ឲ្យអាប្អូនខ្ញុំមួយវាធ្វើទាហ៊ាន វាទៅហៅមកសួរដែរ ។

ឈុនលី ៖ ហើយដល់ពេលនេះគាត់ឆ្លើយថាម៉េច គាត់ចាប់ទៅឲ្យមេសហករណ៍ទៀតហ្អី?

ផាន ៖ បាទ!វាថាបញ្ជូនទៅប្រធានវរៈ ។

ឈុនលី ៖ ហើយពូសួរទេថាមូលហេតុអីបានចាប់?

ផាន ៖ ខ្ញុំសួរគេទៅគេថាយើងរត់ចេញពីអង្គភាពថាវានៅកុមាររត់ចេញពីអង្គភាពវាអត់អីស៊ីវាទៅពឹងបងដើម្បីឲ្យបង ដូចមានអីខ្លះទៅវាហូបទៅមកកន្លែងវិញ ។ ដល់ពេលចឹងទៅគេចាប់យើងបណ្តើរយកមកវិញមក ។ ស្អែកឡើងពីរបីថ្ងៃឡើង ចុះគ្នានៅតូចនោះ រត់ទៅទៀត ។

ឈុនលី ៖ ប៉ុន្មានឆ្នាំពូ?

ផាន ៖ កាលឆ្នាំ៧៣ ប្អូនខ្ញុំប្រហែលនៅអាយុប្រហែល១៤ ១៥ហើយគ្នានៅតូចណាស់ ។ ហើយខ្ញុំស្រណោះប្អូនខ្ញុំណាស់ ប្អូនខ្ញុំកំព្រា ។

ឈុនលី ៖ ហើយធ្វើម៉េចបានមកដល់នេហពូដាច់ដោយឡែកពីគេតែឯងចឹង?

ផាន ៖ ខ្ញុំដោយសារគេបញ្ជូនមក យើងត្រលប់ទៅវិញគឺយើងងាប់កាលណាថាគេបញ្ជូនមកយើងហើយឈ្មោះគេលុបចេញហើយ បើគេឃើញរូបយើងវិញច្បាស់ជាគេសំលាប់យើងចោលហើយ ម្ល៉ោះហើយយើងមក មកតែម្នាក់ឯងគត់ ។ មកម្តាយចុងខ្ញុំដាក់បាយដាក់អីមក ចុះពីលើរទេះភ្លើងវិញគេប្រកាស ឥឡូវអ្នកណាមានគ្រួសារគេដាក់ម៉ាដុំ អ្នកណាអត់មានគ្រួសារ ចុះយើងមកអត់មានគ្រួសារតែយើងឆ្លើយថាមានគ្រួសារគេសួររកគ្រួសារអីចឹងខ្ញុំថាអត់ ដល់អត់គេឲ្យទៅចល័តនៅចំការសាបបី បាចទឹក ។ យើងអ្នកបាចទឹក ម៉ាស៊ីនអ្នកបូប យើងបាចទឹកចេញពីអូរដើម្បីឲ្យម៉ាស៊ីនបូមដាក់ស្រែ គេអត់ឲ្យយើងបាចពីក្នុងប្រឡាយទៅដាក់ស្រែដើម្បីឲ្យម៉ាស៊ីនបូមពីស្រែដាក់អូរទេ គេសុខចិត្តឲ្យម៉ាស៊ីនបូមវិញក្រោយមកទៀតបានគេធ្វើស្រែប្រាំងរួចហើយគេដឹកខ្ញុំឡើងចេះមកភ្នំលាភឡើងភ្នំលាភមកធូន់នឹងទំនប់នេះបានធូន់មែនទែន ។

ឈុនលី ៖ ទំនប់ណាពូ?

ផាន ៖ នេះទំនប់នេះយើងចេញពីភូមិទៅកំបោរ ។

ឈុនលី ៖ គេហៅទំនប់អី?

ផាន ៖ ទំនប់ តាវ៉ាល់ ។

ឈុនលី ៖ ទំនប់ តាវ៉ាល់?

ផាន ៖ បាទ!

ឈុនលី ៖ ហ្អស!

ផាន ៖ មុនដំបូងគេឲ្យយើងលើកម៉ាម៉ែត្រគីបទេណាស ហើយម៉ាម៉ែត្រគីបហ្នឹងជំរៅលើម៉ាម៉ែត្រកន្លះ ។

ឈុនលី ៖ ជំរៅចុះក្រោមម៉ាម៉ែត្រកន្លះ ទទឹងបណ្តោយ?

ផាន ៖ ទទឹងអាបាតវ៉ា៧ បាតវ៉ា១០ ។

ឈុនលី ៖ អត់យល់ យ៉ាងម៉េចវិញពូ?

ផាន : អានេះប្រឡាយចឹងណាស បាតខាងក្រោមគេជីកវារាងទេអីចេះ អានេះបាតវាក្រោម ៧ អាមកពីមាត់ប្រឡាយ១០ម៉ែត្រ ជំរៅម៉ាមែត្រកន្លះ ។ មុនដំបូងគេឲ្យយើងលើកម៉ាម៉ែត្រគីប ម៉ាមែត្រគីបរួចម៉ាថ្ងៃ ស្អែកឡើងពីរម៉ែត្រគីប ពីរម៉ែត្រគីបម៉ាថ្ងៃរួចរហូតដល់ប្រាំម៉ែត្រគីបម៉ោងប្រាំបួនអត់រួចទេ ។ បាយគេឲ្យយើងស៊ីបាយម៉ាវែក ដួសម៉ាវែកមកថ្នាក់មែនទែនអត់មានអ្នកណាឃ្លានបាយទេ ឃ្លានតែទឹកអាទឹកគេយកមកដាំបាយទៅយកចានទៅតំរៀបអាគេដាក់ទឹកបាយកូរអំបិលផឹក ។

ឈុនលី : អត់មានទឹកធម្មតាទេ?

ផាន : អត់ទេ ហើយត្រីលកំភ្លាញម៉ាចានបានតែត្រីកំភ្លាញមួយទេស្ងោរជាមួយបាយ សម្លរយើងហូបជាមួយបាយមានតែត្រីកំភ្លាញមួយទេ ។ ទំរាំតែពេលគេឲ្យខ្ញុំមកនៅនេះ...

ឈុនលី : នៅហ្នឹងបានរយៈពេលប៉ុន្មានពូ?

ផាន : ខ្ញុំនៅនេះ?

ឈុនលី : នៅធ្វើការអាជីកប្រឡាយ ។

ផាន : ជីកប្រឡាយហ្នឹងខ្ញុំនៅបីខែ ។

ឈុនលី : ហើយមានទឹកមុជដែរអត់?

ផាន : ទឹកអត់មានទេ ។

ឈុនលី : បីខែហ្នឹងអត់ដែលមុជទឹកទេ?

ផាន : ទេមានមុជដែរអាទឹកនៅឆ្ងាយពីកន្លែងយើងហូបបាយមកដើរទៅមុជទឹកនៅអាដើមពោធិ៍គេហៅពោធិ៍គូ ហើយមកមុខទៀតមកទប់អូរកាត់អូរវន្ទះបាញ់នេះ ។

ឈុនលី : អាហ្នឹងចូលដល់ឆ្នាំណាហើយពូ?

ផាន : ឆ្នាំ៧៦ ។

ឈុនលី : ៧៦?

ផាន : បាទ!

ឈុនលី : ហើយកាលនោះអ្នកណាគេគ្រប់គ្រងតំបន់នេះ?

ផាន : គ្រប់គ្រងនៅតំបន់នេះ តាវ៉ាល់ ។

ឈុនលី : អ្នកគ្រប់គ្រងឲ្យជីកហ្នឹង?

ផាន : បាទ!

ឈុនលី : ហើយចឹងបានគេហៅថាទំនប់តាវ៉ាល់?

ផាន ៖ បាទ!

ឈុនលី ៖ ជាប់តាំងពីដើមមកម៉ង?

ផាន ៖ បាទ!

ឈុនលី ៖ ចុះអ្នកណាអ្នកគ្រប់គ្រងតំបន់នេះធំម៉ង មេធំ?

ផាន ៖ តំបន់នេះខ្ញុំមិនដែលដឹងគេទេ គេហៅតំបន់ដប់ប្រាំ ហួស!តំបន់ប្រាំ ។

ឈុនលី ៖ ចុះ តាវ៉ាល់ ហ្នឹងឋានៈអីគេ?

ផាន ៖ គាត់នោះឋានៈគាត់ប្រហែលជាគាត់ក្តាប់ចល័ត ។

ឈុនលី ៖ រស់ ញឹម ហ្អី?

ផាន ៖ អត់ដឹងដែរ អត់ដឹងថាអ្នកណាក្តាប់ទេដឹងតែឃុំ ស្រុក ឃុំ ហើយនិងសហករណ៍ ។

ឈុនលី ៖ មេសហករណ៍អ្នកណាគេ?

ផាន ៖ មេសហករណ៍នៅនេះឈ្មោះ តាចាប ។

ឈុនលី ៖ តាចាប?

ផាន ៖ បាទ!តាចាប សព្វថ្ងៃគេចាប់សម្លាប់គាត់អស់ហើយ ។

ឈុនលី ៖ គាត់ហ្នឹងពួកពាយ័ព្យហ្អី?

ផាន ៖ បាទ!សម្លាប់នៅភ្នំ...(ស្តាប់អត់បាន) ។

ឈុនលី ៖ សម្លាប់ហ្នឹងដោយសារអ្នកណាសម្លាប់?

ផាន ៖ ពួកគ្នាគាត់ ។

ឈុនលី ៖ និរតី?

ផាន ៖ បាទ!និរតីគ្នាគាត់

ឈុនលី ៖ ឆ្នាំណាទៅ?

ផាន ៖ ទេ គាត់ស្លាប់ដូចជាខ្ទង់ឆ្នាំ៧៧ ៧៧ ៧៨ព្រោះយើងដូចថាយើងជិតអា...

ឈុនលី ៖ ចុះ តាក្រុក?

ផាន ៖ តាក្រុកក៏គ្នាគាត់ ។

ឈុនលី ៖ គាត់ឋានៈអីគេ?

ផាន ៖ គាត់មេឃុំ ។

ឈុនលី ៖ មេឃុំ?

ផាន ៖ បាទ!

ឈុនលី ៖ គណៈឃុំព្រះនេត្រព្រះ?

ផាន ៖ បាទ!គណៈឃុំព្រះនេត្រព្រះ ហើយ តាម៉ោង នោះគណៈស្រុក ។

ឈុនលី ៖ តាក្រុក ហ្នឹងកាចដែរ?

ផាន ៖ ហួស!កាចណាស់ ។

ប៊ុនម៉ា ៖ ខ្ញុំទៅលើកទំនប់ជាមួយ តាក្រុក ។

ឈុនលី ៖ អីចឹង!ហើយដល់ពេលពូទៅលើកទំនប់ជាមួយ តាវ៉ាល់?

ផាន ៖ បាទ!គាត់នៅប្រចាំការនៅអូររន្ទះបាញ់ ផ្ទះគាត់នៅនឹងអូរ ។

ឈុនលី ៖ ផ្ទះគាត់នៅហ្នឹងអូរ?

ផាន ៖ បាទ រន្ទះបាញ់ហ្នឹង ។ គាត់ធ្វើរោងស័ង្កសីណាស ហើយអាយើងនេះយើងកាប់ដើមឈើ បាំងស្មោអត់ដែលមានសំពត់កៅស៊ូទេ ។

ឈុនលី ៖ ចុះតាយឿម របៀបដូចអនុភូមិហ្អី?

ផាន ៖ តាយឿម នោះគាត់ប្រធានសហករណ៍ តាយឿម ហ្នឹងគាត់ដូចប្រធានសហករណ៍ចឹងដែរ ហើយបើ តាចាប នោះអត់ទេ ។

ឈុនលី ៖ តាចាប ហ្អី?

ផាន ៖ បាទ!ម៉ាយប់ៗចឹងសឹងតែគាត់មិនដេកគាត់ដើរហើយសុទ្ធតែពួកអ្នកនេះហើយ ពួកនិរតី ពួកកំពង់ឆ្នាំង ។

ឈុនលី ៖ ចុះពូមានស្គាល់ យាយចែម ទេ?

ផាន ៖ យាយចែម ថីមិនស្គាល់គាត់គណៈស្រុក ។

ឈុនលី ៖ គណៈស្រុក?

ផាន ៖ គណៈស្រុក ។

ឈុនលី ៖ ធំហើយចឹង?

ផាន ៖ បាទ!ធំ ។

ឈុនលី ៖ យាយចែម ហ្នឹងឋានៈធំជាង តាវ៉ាល់ ទៀត?

ផាន ៖ បាទ! ទេ!យាយចែម ដូចជាគណៈស្រុកហើយ តាវ៉ាល់ គាត់គណៈតំបន់ ។

ឈុនលី ៖ យាយចែម មកក្រោយទេហ្អី?

ផាន ៖ បាទ!យាយចែមគាត់មក...រ្យ

ឈុនលី ៖ យាយចែម គាត់ខាងនិរតីហ្អី?

ផាន ៖ បាទ!យាយថែម ជិនាន់កំពង់ឆ្នាំងពួកកំពង់ឆ្នាំង ។

ឈុនលី ៖ កំពង់ឆ្នាំងហ្នឹងឈ្មោះអីពូ?

ផាន ៖ កំពង់ឆ្នាំងនេះមានពួក តាញ៉ុង ពួកអីដែលគេមកក្ដោបក្ដាប់ធ្វើប្រធានសហករណ៍ប្រធានអីនៅនេះ ។ បើនិរតីមកមុនក៏ប្រធានសហករណ៍ដែរឈ្មោះអីដែរ នារីខ្ញុំ ។ នារីខ្ញុំ ហ្នឹងគាត់នៅ...(ស្ដាប់អត់បាន) ផាប់នឹងនោះលួចអង្ករលួចអីលួចស្រូវលួចអីតែចាប់ហើយព្រលឹមឡើង ហួស!អត់នៅទេ ចាប់ពីដូនប្រែងមកអាប្រធានសហករណ៍គេនៅលើគេវ៉ៃចោល ។ គេវ៉ៃចោលនាងឯងទៅមើលសព្វថ្ងៃគេគាស់ខ្មោចខ្ទីតាមគុម្ពប្ញស្សីគុម្ពអីសុទ្ធតែខ្មោចហើយអាផ្លូវសាលារៀនសុទ្ធតែចំណងផាងត្នោតហើយ ។

ឈុនលី ៖ ពូឃើញគេវ៉ៃទេ?

ផាន ៖ បាទ!ដល់ក្រោយមកទៀតខ្ញុំឈប់នៅឆ្នាំ៧៨ គេឲ្យមកឡើងត្នោតដល់ឆ្នាំ៧៩ ។ មកនេះអត់បេះឡើងអីទេ ខ្ញុំឈប់តែរៀនមកបួសឈប់ពីបួសមកបានប្រហែល៦ខែសឹកមកគេចាប់ធ្វើទាហានដល់ពេលចប់ទាហានចប់នៅភ្នំពេញពេលខ្មែរក្រហមចូលមកភ្នំពេញតែម្ដង ។ ហើយវ៉ៃអាផ្លូវរទេះយើងអាផ្លូវដែកចងទាំងខ្សែយកទៅវ៉ៃ ។

ឈុនលី ៖ ម៉េចបានគេចាប់ទៅ?

ផាន ៖ បើនិយាយទៅគ្រាន់តែយើងលួចដាំដំឡូងខ្ទួនឯង លួចដកដំឡូងមួយគេថាយើងខ្មាំងដឹងតែចាប់វ៉ៃ ហើយហ៊ានតែក្មេងមួយទៅដកគេចាប់វ៉ៃទាំងគ្រួសារហើយ ។ ថ្ងៃមុនពួកយើងអ្នកនៅពោធិ៍ចិនតុងមករកបងប្អូននៅខាងត្បូងគាត់នោះទៅភ្ជួរជាមួយខ្ញុំ ពេលគាត់បរអូសនង្គ័លទៅជិតដើមពោធិ៍នោះគោហ្នឹងរបូតនឹមចេញពីក្បាលវាមកគាត់ឈប់ គាត់ឈប់គេដើរស្រោកមកគេថាឥឡូវគេដាក់នឹមឲ្យគេបោះខ្សែឲ្យគាត់ ចងយកទៅវ៉ៃទាំងថ្ងៃ ។ បងប្អូនមករកគាស់ខ្មោចតែច្រលមកខ្មែររកអត់ឃើញក៏ទៅវិញ ។ ហើយគាត់មួយទៀត... ។

ឈុនលី ៖ អ្នកស្រុកណា?

ផាន ៖ នៅប្រេស ។

ឈុនលី ៖ ស្រេះហ្អី?

ផាន ៖ ប្រេសៗយើង ភូមិប្រេសយើងក្រាំងភ្នំក្រាំងអន្ទ្រងជិតសំរោងនោះ ។

ឈុនលី ៖ ប៉ុយសំរោងហ្នឹងហ្អី?

ផាន ៖ សំរោងឯភ្នំពេញឯណោះ បើរឿងផាប់វិញមិនបាច់ទេនៅភូមិនេះ ។

ឈុនលី ៈ ចុះពូ យាយបែម គាត់មកហ្នឹងមកជាមួយក្រុមនិរតីម៉ងហ្អី?

ផាន ៈ បាទ!ចូលក្នុងក្រុមកនិរតី ។

ឈុនលី ៈ ចឹងគាត់មកហ្នឹងជំនួស គាត់មកដល់មិនធ្វើគណៈស្រុក?

ផាន ៈ បាទ!

ឈុនលី ៈ គណៈស្រុកមុនអ្នកឈ្មោះអី?

ផាន ៈ គណៈស្រុកមុន តាម៉ោង គេចាប់ទៅហើយ ។

ឈុនលី ៈ គេចាប់មុនជាមួយ តាវ៉ាល់ ហ្អី?

ផាន ៈ បាទ!គេចាប់ជាមួយ តាវ៉ាល់ ជាមួយ តាក្រុក ។

ឈុនលី ៈ មេឃុំឈ្មោះអីពូ?

ផាន ៈ តាក្រុក ។

ឈុនលី ៈ តាក្រុក?

ផាន ៈ បាទ!

ឈុនលី ៈ តាវ៉ាល់ ហ្នឹង?

ផាន ៈ ប្រធានចល័ត គាត់ក្តាប់ចល័តម៉ាតំបន់ហ្នឹង គាត់មានសិទ្ធិម៉ាតំបន់ប្រាំហ្នឹងគាត់មានសិទ្ធិទាំងអស់ ។ ចាប់ពួកគាត់នៅភ្នំតាយោង ។

ឈុនលី ៈ តាយោង?

ផាន ៈ បាទ!តាយោងយើងភ្នំលាកហ្នឹង?

ឈុនលី ៈ នៅឃុំអីគេអាហ្នឹង?

ផាន ៈ នៅភ្នំលាក ពីដើមតាយោងហ្នឹងមានគុមកមួយដែរសំរាប់ដាក់កម្មាភិបាល ។

ឈុនលី ៈ ឥឡូវនៅទេពូ?

ផាន ៈ មិនដឹងយ៉ាងណាបាត់អស់ហើយដឹង បើប្រជាជនគេគាស់កកាយធ្វើកន្លែងធ្វើផ្ទះធ្វើសំបែង ។

ឈុនលី ៈ ប្រជាជនចាប់ផ្តើមទៅគាស់នៅពេលណា?

ផាន ៈ ពេលប្រហែលជាយើងចប់៧៩ ។

ឈុនលី ៈ អាហ្នឹងនៅលើភ្នំហ្អី?

ផាន ៈ បាទ!គេដាក់គុកនៅលើភ្នំ ។

ឈុនលី ៈ ចុះម៉េចបានពូដឹងថាគេយកទៅសំលាប់ចឹង?

ផាន ៖ ចុះបើអ្នកទោសទាំងប៉ុន្មានយកទៅតាយោង តាយោងជាកន្លែងគុក ។

ឈុនលី ៖ ជិតប្តូ ឆ្ងាយ ។

ផាន ៖ ឆ្ងាយ អាផ្លូវយើងទៅតាមផ្លូវសៀមរាបនេះគេហៅភ្នំលាភ មើលទៅខាងត្បូង ។

ឈុនលី ៖ មើលទៅឃើញភ្នំហ្នឹង?

ផាន ៖ បាទ!ភាគច្រើនឲ្យតែយកទៅដាក់នៅភ្នំតាយោងដឹងតែទៅហើយ អាហ្នឹងគុកដូចថា ឧទាហរណ៍ថា ខ្ញុំអីចឹងខុសភ្លាមគេយកទៅវ៉ៃចោលភ្លាម តែបើកម្មាភិបាលបើខុសគេយកទៅរៀនសូត្រ ហើយប្រជាជនយើងម៉ាចំនួនទៀតថាទៅដឹកអំបិលដឹងថាស្រេចហើយ ។ ដឹកអំបិលដឹកអង្ករដឹកអីដឹងតែស្លាប់ហើយ ។ ប្រជាជនយើងមកពីភ្នំពេញដឹងតែចង់ទាំងខ្សែទៅវ៉ៃស្មើណាក៏វ៉ៃដែរ ហើយបើកម្មាភិបាលគេយកទៅគរគ្នា ។

ឈុនលី ៖ អ្នកស្រុកយើងយកទៅវ៉ៃចោលនៅហ្នឹងទៅ?

ផាន ៖ បាទ!មានឆ្ងាយអីនៅជិតភូមិនេះ ។

ឈុនលី ៖ ចឹងយាយថែមគាត់មកហ្នឹងជិន្ទូសអ្នកណាខ្លះទៅ អ្នកណាគេគណៈឃុំ?

ផាន ៖ ឃុំនេះកាល យាយថែម គាត់មក តាក្រក គេអត់ទាន់ដកទេព្រោះអីអាហ្នឹងគេលាក់ការផ្ទៃក្នុងរបស់គេ គេដកមួយចេញសិនគេទុកមួយនៅសិនទៅណាស ។ ដល់ក្រោយមកតាក្រក ចុងបញ្ចប់គេចាប់តាក្រកទៅ ។ ដក តាក្រកទៅជិតដល់អាយើងឲ្យវៀតណាមអីមកអាហ្នឹងបាន តាក្រក ហ្នឹងគេចាប់ផ្តើមចាប់ពីពេលនោះទៅ ។ ហើយពេលចាប់តាក្រក ទៅពួកខ្ញុំក៏អត់ហ៊ាននៅដេកផ្ទះដែរនាំគ្នារត់ព្រោះយប់ឡើងវាកៀរពួកមេក្រុមមេកងមេអីឡើងទៅភ្នំមកូនខ្វែង ដល់ទៅនោះវេទនាទៀតមេក្រុមម៉ាចំនួនរត់មកវិញមកដល់តែរត់មកទៅ ទាំងគេទាំងខ្ញុំចុះព្រុថាយប់ឡើងវៀតណាមក៏មកហើយវាក៏មកដែរ វាមកវាមកចាប់កៀរយើងយកទៅ ។ ពួកមេក្រុមដែលមកគេថាទៅអត់រួច វាទ័ពវាប្រុងទៅថៃអត់រួច វាទ័ពវាប្រុងទៅថៃអត់រួចទល់នឹងទាហានខ្មែរយើងរណៈសិរ្សមក វាត្រូវយកយើងទៅដាក់នៅមុខ គេឲ្យយើងទៅចឹងទៅដើម្បីទាហានខ្មែរយើងឃើញប្រជាជនអត់ហ៊ានបាញ់ណាស ចឹងមិនដែលហ៊ានដេកអីទេប្អូនដប់យប់ដឹងថាវៀតណាមគេឡើងមកតាមសៀមរាបតាជប់អីហើយបានអ្នកស្រុកហ៊ានដេក ពេលដែលខ្ញុំរត់មិនដែលបានដេកផ្ទះទេ ។

ឈុនលី ៖ ចុះពូម៉េចអត់បានទៅធ្វើនៅទំនប់ត្រពាំងថ្មចឹង?

ផាន ៖ ព្រោះខ្ញុំទៅនៅជាប់ វាមានពីរផ្នែកចល័តពួកខ្ញុំនេះគេហៅចល័តតំបន់ ហើយចល័តតំនបន់ហ្នឹងនៅយើងទំនប់កំបោរស្រែះដល់ពួកត្រពាំងថ្មគេហៅចល័តពួកស្រុក និងពួកឃុំ និងសហករណ៍ ។

ឈុនលី ៖ ស្រុក ឃុំ សហករណ៍ហ្នឹងទៅត្រពាំងថ្ម?

ផាន ៖ បាទ! ទៅត្រពាំងថ្ម ។

ឈុនលី ៖ ហើយចល័តតំបន់ហ្នឹងនៅលើកក្នុងស្រុក ។

ផាន ៖ បាទ!តំបន់នៅតាមនេះ អាកន្លែងណាដែលតំបន់គេត្រូវការគេយកពួកតំបន់នេះទៅចល័ត ។

ឈុនលី ៖ សុទ្ធតែប្រុសៗឬយ៉ាងម៉េច?

ផាន ៖ ប្រុសស្រីដូចគ្នាទាំងអស់កូនក្មេង ។

ឈុនលី ៖ ចុះកំណត់យ៉ាងម៉េច អ្នកថ្មីអ្នកចាស់ឬយ៉ាងម៉េច?

ផាន ៖ បាទ!ដល់ពេលនោះយើងមកលើកអីចេះគេអត់មាន សុទ្ធតែពួកអ្នកថ្មីហើយ បើសិនជាអ្នកចាស់គឺឡើងដល់ប្រធានកង ។

ឈុនលី ៖ ហើយបើអត់បានឡើងប្រធានកងទេទៅខាងត្រពាំងថ្មគេហៅចល័តស្រុកអីហ្នឹង?

ផាន ៖ បាទ!អ្នកដែលទៅជាប្រធានកងគេហៅកងរយៗហ្នឹងសុទ្ធតែអ្នកមូលដ្ឋានទេ បើយើងមកពីភ្នំពេញគឺយើងកូនចៅគេទាំងអស់ ។

ឈុនលី ៖ អីចឹងទៅលើប្រឡាយ តាវ៉ាល់ ហើយកំបោរស្រែះហ្នឹងដូចគ្នាឬផ្សេងគ្នា?

ផាន ៖ ដូចគ្នា ។

ឈុនលី ៖ ពីរហ្នឹងឈ្មោះដូចគ្នា?

ផាន ៖ បាទ!

ឈុនលី ៖ ចុះម៉េចក៏គេហៅអីចឹង?

ផាន ៖ គេជាប់តាំងពីសម័យបីឆ្នាំមកគេហៅទំនប់ តាវ៉ាល់ៗចឹងណាសព្រោះ តាវ៉ាល់ គាត់កាន់ក្តាប់នៅនោះ ទំនប់ខ្វាំង ។

ឈុនលី ៖ ខ្វាំងហ្នឹងខ្វាំងត្រង់ណាវិញ?

ផាន ៖ គាត់ហ្នឹងបើថាគាត់ត្រូវឲ្យរ៉ៃៗ អត់មានថាប្រកែក គ្រាន់តែទំបន យើងបិទអូរគាត់ដាក់ឲ្យ៧កងធំបីថ្ងៃឲ្យរួច បើមិនរួចទេគាត់ដកចេញបីកងទុកតែប៉ុន្មានកងឲ្យលើកទៅ គាត់អត់មានថែមទេ គាត់ដកចេញគាត់បញ្ជាខ្វាំង បើថាត្រូវរ៉ៃៗបើថាត្រូវដង្ហើរម៉េច ធ្វើម៉េច

ចេញ ។ គាវ៉ាល់ កាចអ្នកណាមួយដែលថាទេ នៅចល័តពុតែ គាវ៉ាល់ ខ្លាចទាំងគេទាំង ខ្ញុំ ។

ឈុនលី : គាវ៉ាល់ ហ្នឹងខ្មែរទេតើហ្អី?

ផាន : ខ្មែរយើង ។

ឈុនលី : អ្នកស្រុកហ្នឹងដែរហ្នឹង?

ផាន : គាត់មិនមែននៅស្រុកយើងទេ នៅតំបន់ស្រុកយើងនេះអត់មានអ្នកណាធ្វើតួនាទី និយាយទៅស្រុកយើងនេះគេថាតំបន់១៧មេសា ។

ឈុនលី : ចឹងអ្នក១៧មេសា ប្រជាជនថ្មីត្រូវទៅលើកទំនប់ដូចពូដែរ?

ផាន : បាទ!

ឈុនលី : អត់មានអ្នកចាស់ទេ?

ផាន : អត់ទេ ។

ឈុនលី : អ្នកចាស់គេជម្លៀសចេញដូចមីងអីចឹង?

ផាន : បាទ!អ្នកចាស់ដូចថា និយាយរួមអ្នកភូមិនេះគេចាត់ចឹងណាស ប្រជាជនចាស់ប្រជាជនថ្មី នៅនឹងភូមិនេហបានន័យថាប្រជាជនថ្មី ហួស!ប្រជាជនចាស់ ហើយដល់ពេលពួកខ្ញុំមកពី ខាងនោះមកដូចថាប្រជាជនជម្លៀសនៅនេះច្រើនណាស់...ក៏នៅជើងភ្នំនេះក៏នៅច្រើនណា ស់សុទ្ធតែអ្នកថ្មី ។ ពួកយើងអ្នកថ្មីនេះទៅតាមតំបន់ អ្នកមូលដ្ឋាននេះគេឲ្យទៅខាងត្រពាំង ថ្ម ហើយក្រោយមកទៀតយើងប្រមូលចេញអស់ពីត្រពាំងថ្មពីអីអស់ហើយបានគេឲ្យចាប់ ផ្តើមធ្វើចំការម្តង ។ ធ្វើចំការខ្ញុំទៅគាស់គល់នៅត្រពាំងកក់នេះ៩ម៉ែត្របួនជ្រុងគេឲ្យធ្វើម៉ា ដៃ អាគល់ប៉ុនៗណោះ៩ម៉ែត្របួនជ្រុងគាស់គល់ ។

ឈុនលី : គាស់គល់ធ្វើអី?

ផាន : គាស់គល់ធ្វើចំការបានកើតជាចំការដូចសព្វថ្ងៃ ។

ឈុនលី : កាលនោះគេដាំអីគេពូ?

ផាន : ចំការនោះមានអីទេ មានដាំដំឡូងមីអីណាស ដាំតែដំឡូងមី ។ យើងដាំដំឡូងមី ដាំមែន តែមិនដែលបានហូប ។ អ្នកថ្មីមកនេះស្លាប់ច្រើនណាស់ ។

ឈុនលី : ពូមានដឹងរឿងត្រពាំងថ្មហ្នឹងអ្នកណាអ្នកចាត់ចែងឲ្យធ្វើ? ត្រពាំងថ្មហ្នឹងគេធ្វើមុនពេល យាយចែម មកទៀតហ្អី?

ផាន : បាទ!មុនៗ យាយចែម ។

ឈុនលី ៖ ចុះអ្នកណាចាត់ចែងឲ្យធ្វើ?

ផាន ៖ កាលពីជំនាន់ តាម៉ោង តាម៉ោង ចៅហ្វាយស្រុកមុនណាស់ គាត់មុនយាយចែម ។

ឈុនលី ៖ ចឹងគាត់អ្នកផ្តើមគំនិតឲ្យធ្វើ?

ផាន ៖ បាទ!

ឈុនលី ៖ ហើយមានជំនួយការមកពីណាណីជួយទេ?

ផាន ៖ អត់ទេ ។

ឈុនលី ៖ មានវិស្វករមកជួយគូសប្លង់គូសអីអត់?

ផាន ៖ អត់ទេ ប្រើកំលាំងផ្ទាល់គំនិតរបស់គាត់ ។ គំនិតពី តាវ៉ាល់ តែមានម្នាក់ទៀតជា បើយើងនិយាយមកសព្វថ្ងៃគាត់ជាសាស្ត្រាចារ្យ ។ គាត់ហ្នឹងអ្នក តាវ៉ាល់ ថាលើកទំនប់ពីនេះទៅកំបោរគាត់ហ្នឹងអ្នកគំរង់តែម្តង គាត់អត់យកអីទេគំរង់តែភ្នែកខ្លួនគាត់ គំរង់ភ្នែកត្រង់ភ្លឹង ដោតឈើពីនេះទៅដាក់ឬស្សីចងក្រមាយើងទៅគាត់អ្នកគំរង់គាត់អ្នកគំរង់ឲ្យអ្នកកាន់បង្គោល ។

ឈុនលី ៖ គាត់អ្នកវាស់វែងម៉ង?

ផាន ៖ បាទ!អត់មានវិស្វករណាមកទេ ។

ឈុនលី ៖ ចុះដល់ពេលអាធំនេះ ត្រពាំងថ្ម?

ផាន ៖ ត្រពាំងថ្មក៏អត់មានវិស្វករណាមកដែរ ។

ឈុនលី ៖ តាម៉ោង ហ្នឹង?

ផាន ៖ បាទ!

ឈុនលី ៖ ម៉េចបានឮដឹងថា តាម៉ោង អ្នកវាស់វែង?

ផាន ៖ ចុះគាត់គណៈស្រុកព្រះនេត្រព្រះ បើនិយាយទៅតាមខ្ញុំគិតដែលថាតាមគំនិតគាត់ធ្វើអីចឹងគេចង់ធ្វើអាសំណង់ទឹក សំណង់ទឹកដូចភ្នំកូនខ្វែង បើយើងនិយាយទៅអាហ្នឹងមិនមែនគោលដៅវាប្រុងធ្វើអីទេ គឺពេលមានបញ្ហាគឺគេរត់នៅព្រៃនោះគេបានទឹកស្រេច ដូចតា ម៉ុក គាត់ទៅនៅអន្លង់វែងចឹងឃើញទេ គាត់មិនមានស្រះទឹកស្រេច ។ ព្រៃកូនខ្វែងហ្នឹងធំណាសណា ។

ឈុនលី ៖ ប្រហែលប៉ុន្មានហិចតាទៅ?

ផាន ៖ ប្រហែលម្ភៃសាមសិនហិចតា ។

ឈុនលី ៖ ប៉ុន្តែអាត្រពាំងថ្មហ្នឹងធំទេ?

ផាន : បាទ! ត្រពាំងថ្មហ្នឹងធំ ។

ឈុនលី : បណ្តោយទទឹងប៉ុន្មានពូដឹងទេ?

ផាន : អត់បានដឹងទេ តែយើងមើលពីលើទៅឆ្ងាយណាស់ ។

ឈុនលី : ដាច់កន្ទុយភ្នែក?

ផាន : ដាច់កន្ទុយភ្នែក តែគ្រាន់តែថាមានរាក់មានជ្រៅ កន្លែងណាដែលគេកកាយដីកយកដីដាក់ទំនប់នោះវាជ្រៅ អាកន្លែងណាដែល... កណ្តាលរាក់វិញ ជ្រៅតែជើងទំនប់ទេ ។ ខែប្រាំងត្រឹមក លេចក្បាល ។ បើទៅឆ្ងាយទៅទៀតរាក់ព្រោះដូចវាបិទទៅយកទឹក...។ បើតាមខ្ញុំគិតទៅប្រហែលជាកាលនោះ អើបើយើងនិយាយទៅថាសម័យគេនោះ...។

ប៊ុនម៉ា : បើនិយាយពីទទឹងបណ្តោយអត់អ្នកណាដឹងទេ បើយើងខ្វាចគេ គេឲ្យលើកចេះតែលើកទៅ

ឈុនលី : បើគិតទៅចាប់ផ្តើមធ្វើពីពេលណាមកអាងត្រពាំងថ្ម?

ផាន : ទេ ត្រពាំងថ្មចាប់ផ្តើមពេលវាចូលមកនៅនេះតែម្តង ចាប់ផ្តើមលើកអាទំនប់នេះ...៧៧ ។

ឈុនលី : ពេលហ្នឹង យាយចែម មកនៅ?

ផាន : នៅទេ យាយចែម គាត់មកប្រហែលម៉ាររយៈក្រោយ ។

ប៊ុនម៉ា : ខ្ញុំនៅជាមួយ គាញ៉ុន ទៅលើកទំនប់នៅគោករំចេកឆ្នាំ៧៦ ៧៦ខ្ញុំទៅត្រពាំងថ្មបានប្រហែលជិតម៉ាខែខ្ញុំមកវិញ ខ្ទង់ច៧៧ហើយត្រពាំងថ្ម ។

ឈុនលី : ហើយមីងទៅនោះសភាពការណ៍ម៉េចខ្លះទៅមីង អត់ទាន់ធ្វើអីឯណាហ្អី?

ប៊ុនម៉ា : អត់ទាន់ធ្វើអីទេ ។

ឈុនលី : នៅវាលនៅឡើយទេ?

ប៊ុនម៉ា : ហ្នឹងហើយនៅវាល ចាប់ផ្តើមធ្វើ ។

ឈុនលី : ចាប់ផ្តើមធ្វើ ហើយគេជម្លៀសទៅហ្នឹងប៉ុន្មាននាក់ទៅ?

ប៊ុនម៉ា : គេជម្លៀសភូមិនេះទៅច្រើនណាសនាង អត់បានចាំទេ ទៅសេរីពួកខ្ញុំណាស ។

ឈុនលី : ប្រហែលប៉ុន្មាននាក់ទៅ?

ប៊ុនម៉ា : ប្រហែលសាមសិបនាក់ ។

ឈុនលី : តិចម្ល៉េះ?

ប៊ុនម៉ា : ចុះមិនមែនមានតែភូមិយើងឯណា ។

ឈុនលី : ដល់ពេលយើងទៅដល់សរុបចូលគ្នាប៉ុន្មានទៅ?

ប៊ុនម៉ា : បំបែក គេអត់មានឲ្យនៅជុំគ្នាទេ ។ មនុស្សនៅកន្លែងនោះនស?

ឈុនលី ៖ ចាំ! ពេលដែលមីងទៅកន្លែងត្រពាំងថ្មហ្នឹង អ្នកដែលទៅធ្វើការជាមួយមីង អ្នកផ្សេងទៀតហ្នឹងណាស ។

ប៊ុនម៉ា ៖ មនុស្សប៉ុន្មានទេប្អូនអើយ មិនដឹងប៉ុន្មានទេ ។

ឈុនលី ៖ រាប់ម៉ឺនទេ?

ប៊ុនម៉ា ៖ រាប់ម៉ឺនរាប់ពាន់ រាប់គ្មិស ។

ដាន ៖ គេប្តូរ គេប្តូរវេនគ្នាណាសថាឥឡូវគេបញ្ជារមេភូមិថាយកកំលាំងប៉ុន្មានហ្នឹងអ្នកទៅហើយកំណត់ប៉ុន្មានគេត្រលប់មកបរិញ មិនមែនថាគេកំណត់ឲ្យយើងទៅលើសតែម្តងទេណាស នេះពួកមូលដ្ឋានណាស ។ បើថាយើងអ្នក វាទៅឯណោះវាចំរុហអ្នកមូលដ្ឋានចំរុះអ្នកថ្មី ។

ប៊ុនម៉ា ៖ ដូចថាខ្ញុំទៅម៉ាខែបីងខ្ញុំមកវិញហើយ ត្រូវយកនាងឯងទៅម្តង ។

ឈុនលី ៖ ចុះមីងទៅវិញទៀតទេ?

ប៊ុនម៉ា ៖ អត់បានទៅទេ ។

ឈុនលី ៖ មកតែម្តងៗទេ?

ប៊ុនម៉ា ៖ ហ្នឹងឯងមកតែម្តងទេ?

ឈុនលី ៖ ហើយទៅដំបូងគេចែកប៉ុន្មានម៉ែត្រទៅម្នាក់?

ប៊ុនម៉ា ៖ ម្នាក់ម៉ាម៉ែត្រគីប ។

ឈុនលី ៖ ម៉ាម៉ែត្រទេ?

ប៊ុនម៉ា ៖ ហ្នឹងឯង ។

ឈុនលី ៖ មិនមែនបីម៉ែត្រទេ?

ប៊ុនម៉ា ៖ ទេ ក្រុមខ្ញុំម្នាក់តែម៉ាម៉ែត្រទេ ។

ឈុនលី ៖ អាហ្នឹងយ៉ាងម៉េចអ្នកណាបីម៉ែត្រអ្នកណាម៉ាម៉ែត្រអីចឹងទៀត?

ប៊ុនម៉ា ៖ ហ្នឹងឯង ចែកតាមក្រុម ។

ឈុនលី ៖ ចុះហេតុអីក្រុមមីងបានតិចជាងគេ?

ប៊ុនម៉ា ៖ ក្រុមមីងគ្នាតិចទៅវាសំបូរអ្នកល្អិតៗ មនុស្សតូចណាស ម្លោះហើយគេដាក់តាមមនុស្សតូចនោះម្លោះហើយគេដាក់តាមមនុស្សតូចហើយ ពួកខ្ញុំអីអត់ទាន់ធំទេកាលនោះ ។

ឈុនលី ៖ ម៉ាម៉ែត្រគីប?

ប៊ុនម៉ា ៖ ម៉ាម៉ែត្រគីបគេឲ្យយើងរែក ។

ឈុនលី ៖ អាហ្នឹងគេគិតម៉េច ទទឹងបណ្តោយប៉ុន្មាន?

ប៊ុនម៉ា ៖ ម៉ាម៉ែត្រគីបបួនជ្រុង ។

ឈុនលី ៖ ទទឹងម៉ាម៉ែត្រ បណ្តោយម៉ាម៉ែត្រ ជំរៅ?

ប៊ុនម៉ា ៖ ជំរៅម៉ាម៉ែត្រ ។

ឈុនលី ៖ ជំរៅម៉ាម៉ែត្រដែរ?

ប៊ុនម៉ា ៖ ចាស៎

ឈុនលី ៖ ចុះមានអ្នកខ្លះបីម៉ែត្រចឹងដែរអត់?

ប៊ុនម៉ា ៖ បីម៉ែត្រមាន ។

ឈុនលី ៖ អ្នកធំៗ?

ប៊ុនម៉ា ៖ ហ្នឹងឯង ខ្ញុំធ្វើម៉ាម៉ែត្រគីបហើយអីចេះ ស្អែកឡើងឡើងកន្លះម៉ែត្រទៀត ខានស្អែកឡើងឡើងកន្លះទៀត ។ បើសិនជាយើងវែកអត់រួច គេធ្វើបាបយើង ។

ឈុនលី ៖ ធ្វើម៉េច?

ប៊ុនម៉ា ៖ គេបញ្ជាយើងស្រេចតែគេស្រែកសំឡុតប្រមាថយើង ។

ឈុនលី ៖ ធ្វើដល់យប់?

ប៊ុនម៉ា ៖ ហ្នឹងឯង ។

ឈុនលី ៖ ហើយមីងដែលធ្វើដល់យប់ទេ?

ប៊ុនម៉ា ៖ ធ្វើដល់ម៉ោង៧ ម៉ោង៨អីរួចហើយ ។

ឈុនលី ៖ មីងធ្វើរួចដែរ?

ប៊ុនម៉ា ៖ រួច ដល់រួចហើយឡើងទៅហូបបបរ គេវាល់ ។

ឈុនលី ៖ ឲ្យហូបបបរទេមិនមែនហូបបាយទេ?

ប៊ុនម៉ា ៖ ហូបបបរ កន្លែងខ្ញុំហូបបបរ ហូបបបរក៏វាល់ម៉ាកូនចានចង្កឹះចែកគ្នា ។

ឈុនលី ៖ បបរខាប់ឬរាវ?

ប៊ុនម៉ា ៖ បបររាវ

ដូចថាដប់កំប៉ុងអីចឹងក្នុងគ្នា៣០នាក់ក៏ហូបទៅ១០កំប៉ុងប៉ុណ្ណោះឯងអត់មានបានលើសពីនោះទេ ។

ឈុនលី ៖ បបរដប់កំប៉ុង៣០នាក់?

ប៊ុនម៉ា ៖ នោះឯង បបរវាល់ចែកគ្នាបើថាម៉ាវែកម៉ាវែកដូចគ្នាពីរវែកៗទាំងអស់គ្នា ។

ឈុនលី ៖ ហើយបានម្ហូបអីគេ?

ប៊ុនម៉ា ៖ គេមានប្រហុក គេមានកូនត្រីគេយកមកពីអីយកមកឲ្យយើងហូបបបរហ្នឹងឯង មិនដែលស្គាល់ជាតិសម្ល‌រទេ មិនដែលស្គាល់ជាតិសម្លរជាតិសាច់យ៉ាងណា បើពងត្រីនិងប្រហុកមានមិនដឹកមកពីណាទេ ។

ឈុនលី ៖ អីចឹងមីងនៅក្នុងកងគេហៅកងចល័តស្រុកហ្អី?

ប៊ុនម៉ា ៖ ចល័តស្រុក កងចល័តស្រុកតែដូចគេកាម៉ង់កំលាំងយើងពីនេះណាស ដឹងថាគេធ្វើពីនោះអត់រួចគ្នាតិចគេកាម៉ង់កំលាំងយើងទៅតាមភូមិហ្នឹងឯងយកទៅប្រមូលគ្នាធ្វើការ ។ ភ្លៀងនោះនាងអើយ! ដេកត្រាំទឹកត្រាំភក់ ។

ឈុនលី ៖ មានទឹកហូបគ្រប់គ្រាន់ទេនៅនោះ?

ប៊ុនម៉ា ៖ ទឹកមានហូបនោះឯងទឹកដែលយើងជីកធ្វើទំនប់ ។

ឈុនលី ៖ ចុះក្រែងគេចែកទេតើហ្អី?

ប៊ុនម៉ា ៖ ហ្នឹងហើយគេចែក ទឹកភ្លៀងទឹកអី ។

ឈុនលី ៖ គេចែកប៉ុណ្ណា?

ប៊ុនម៉ា ៖ ទឹកក៏គេចែក ប៉ះណាក៏គេដងឲ្យយើងម៉ាកូនពែងប៉ុណ្ណោះមក ប៉ះណាក៏វាល់ស្លាបព្រា ។

ឈុនលី ៖ ប៉ុន្មានស្លាបព្រា?

ប៊ុនម៉ា ៖ បានម្នាក់បីស្លាបព្រាបួនស្លាបព្រា ។

ឈុនលី ៖ ហូបម៉េចឆ្អែតទៅ?

ប៊ុនម៉ា ៖ នោះឯង ហូបមិនឆ្អែតទេ វេទនាណាស់ ។

ឈុនលី ៖ ចុះមានមុជទឹកដែរអត់?

ប៊ុនម៉ា ៖ ទឹកក៏មុជតាមក្រឡេកក្រឡុកដែលយើងត្រាំទឹកហ្នឹងហើយ ដូចថាយើងដេកចឹងវាលស្រែមានទឹកដក់ចឹងក៏មុជទៅណាសតាមក្រឡេកក្រឡុកហ្នឹង ។

ឈុនលី ៖ តិចតួចហ្នឹង?

ប៊ុនម៉ា ៖ ចា៎!ចេះតែមុជទៅ ប៉ះណាពីរបីថ្ងៃបានមុជម្តង ។ ទៅលើកទំនប់ចឹងទៅភ្លៀងទឹកសើមក៏ផ្លាស់ទៅដេកទៅណាស នាំគ្នាដេកទៅ ។

ឈុនលី ៖ អត់មានចៃទេ?

ប៊ុនម៉ា ៖ ចៃថាក្អែល និយាយទៅទឹកភ្អែកណាសនាង! វែកមិនរួចទេខ្ញុំកាលនោះតូចជាងគេ ។

ឈុនលី ៖ មីងតូចជាងគេហ្អី?

ប៊ុនម៉ា ៖ តូច មិនបានធំបានថិតដូចសព្វថ្ងៃទេ ។

ឈុនលី ៖ ហើយគេឲ្យមកលេងផ្ទះអីអត់ទេ?

ប៊ុនម៉ា ៖ អត់ឲ្យទេ អត់ដែលឲ្យមកលេងឃើញមុខម៉ែឪយ៉ាងណាអត់ឲ្យ បើគេបញ្ជាឲ្យទៅបាន ។ បើយើងទៅម៉ាខែអីចេះដឹងតែម៉ាខែ ។

ឈុនលី ៖ ចុះអ្នកណាអ្នកមើលការខុសត្រូវនៅនោះមើលទំនប់ហ្នឹងធំអីចឹង?

ប៊ុនម៉ា ៖ ទំនប់នោះធំណាស់ កាលនោះនៅតូចមើលចាំមិនបានទេ មិនដឹងរឿងអីហ្នឹងគេទេដឹងតែគេឲ្យធ្វើចេះតែធ្វើប៉ុណ្ណោះឯង ។

ផាន ៖ គ្មានអ្នកណាហ៊ានសួរអីទេ ពួកខ្ញុំនេះដឹងដោយសារព្រលឹមឡើងគាត់ប្រកាសមេក្រូហើយ ។

ឈុនលី ៖ អ្នកណាគេអ្នកប្រកាសពូ?

ផាន ៖ តាវ៉ាល់ កាលគាត់នៅនេះ ។

ឈុនលី ៖ គាត់ប្រកាសខ្លួនឯងម៉ងហ្អីពូ?

ផាន ៖ បាទ!គាត់ប្រកាសខ្លួនឯង គេចាក់ឲ្យក្រោកពីព្រឹក ម៉ោង៦ឡើងដឹងតែក្រោកហើយ ។ ហើយបើគាត់ទៅសំរាកប្រជុំហើយណាស គាត់ហៅបុគ្គលិកទាំងអស់មកប្រជុំថាប្រជាជនថ្មីអ្នកណាដែលមានអ្នកណាដែលចង់ធ្វើការធំជុំហ្នឹងកុំឲ្យចង់ណាស ។ ការងារយើងក្រដាសប៊ិចយើងគឺដងចប ក្រដាសគឺដី គាត់និយាយអីចឹង អត់មានថាចង់…ហួស!មានដែរមានម៉ាចំនួនដែលចង់ទៅ ខ្លះចង់ទៅខាងខគុនិយម ខ្លះចង់ទៅខាងអីផ្សេងៗ ។ ចង់ទៅគេហៅទៅមែន ឡើងទៅគេយកទៅវៃចោលនៅនឹងជិតមាត់ស្ទឹងយើងអន្ទង់សារយើងនេះដុបអាព្រៃរបោះយើងអស់ពីរម៉ក អ្នកដែលចង់ទៅធ្វើការទៅភ្នំពេញវិញ ។

ឈុនលី ៖ អាហ្នឹងគេសួរពេលប្រជុំហ្អី?

ផាន ៖ បាទ!គេហៅមកសួរដូចសួរខ្ញុំចឹងថាឥឡូវមិត្តណាធ្វើអីខ្លះ? ខ្លះក៏លើកដៃគេសួរថាមិត្តឯងទៅខាងអី? ថាខ្ញុំទៅខាងភ្លើងឬមួយក៏ខាងបើកកឺ ។ ចឹងគេថាស្អែកម៉ោង៧មកចាំនៅកន្លែងអាយើងពីកំបោរស្រែះមកអូរវន្ទះបាញ់ រោងគាត់នៅនោះ ត្រាក់ទ័រទៅចាំទៅដឹកយកទៅ ឡើងទៅៗវៃចោលនៅជិតអន្ទង់សារហ្នឹង ។

ឈុនលី ៖ មានអ្នកណាដឹងរឿងនោះទេភ្លាមៗហ្នឹង?

ផាន ៖ ដឹងរឿង ។

ប៊ុនម៉ា ៖ ពូដឹងទេ?

ផាន ៖ បាទ!ដឹង ។

ឈុនលី ៖ ហេតុអីបានពូដឹង?

ផាន ៖ អាអ្នកដែលនៅតាមភូមិជាពិសេសអ្នកទៅកាប់អុសនៅចល័តវាឃើញ ។

ឈុនលី ៖ ឃើខ្មោចហ្អី?

ផាន ៖ បាទ! ឃើញខ្មោច ។

ឈុនលី ៖ អត់កប់ទេ?

ផាន ៖ ចុះរណ្តៅគេធំគេអត់ទាន់កប់នោះគេទុកឲ្យបានច្រើន ។

ឈុនលី ៖ អីចឹងមិនវ៉ៃហើយដាក់ចោល ទៅមើលទៅឃើញ?

ផាន ៖ បាទ! វាមានបានគិតថាយើងនេះអី វាបានតែវ៉ៃចោលហើយវាវ៉ៃទៅអត់គិតថាយើងខ្លាច អាហ្នឹងធ្វើឲ្យយើងអ្នកក្រោយៗវាខ្លាច ។

ឈុនលី ៖ បាក់ស្បាត!

ផាន ៖ បាទ! បាក់ស្បាត ហើយខ្ញុំឃើញទាំងតានោះទៀត គាត់ហ្នឹងអ្នកលក់គុយទាវអីផ្សារអន្លង់ស្នួលអីណោះ ។ គាត់លើកដៃឡើង គាត់ថា គាត់សួរថា តាឯងខាងអី? គាត់ថាបើកឡាន! អីចឹងចាំទៅបើកឡានឲ្យខ្ញុំ ខ្ញុំនៅឡានមួយ ។ តានោះគាត់ស្មានតែរួចខ្លួន ។

ឈុនលី ៖ អីចឹងតាហ្នឹងទៅបើកឡានមែន?

ផាន ៖ ទេ អត់ទេគាត់មិនបានយកទៅណាទេ បើកឡានបើកអីព្រោះតានោះគាត់ចាស់ទៅហើយ យកគាត់ទៅធ្វើវែកដីដែរ ។ ផុតពីនោះទៅអត់អីទេ ក្មេងចាស់ដូចថាធ្លាប់ចល័តជុំខ្ញុំធ្លាប់ដេកជុំគ្នាណាសប្រាប់ថាកុំចង់ទៅអី គេថា មិនដែលមាន សម័យនេះគេយកអ្នកបើករទេះគោទៅបើកកប៉ាល់ហោះទេ ទៅដឹងតែងាប់ហើយ ។

ឈុនលី ៖ ពូកាលនោះរៀនបានថ្នាក់ទីប៉ុន្មាន?

ផាន ៖ ថ្នាក់ទី៦ រៀនអីស្រុកបានថ្នាក់ទី៦ ។

ឈុនលី ៖ ហើយសព្វថ្ងៃពូធ្វើគ្រូ?

ផាន ៖ បាទ!

ឈុនលី ៖ គ្រូថ្នាក់ទីប៉ុន្មាន?

ផាន ៖ អត់ទេ សព្វថ្ងៃនាយក ។

ឈុនលី ៖ ហួស! នាយក?

ផាន ៖ ប្រាំសាលា ប្រាំភូមិ ។

ឈុនលី ៖ នាយកសាលាអីគេពូ?

ផាន ៖ សាលាស្រះលិច ។

ឈុនលី ៖ បឋមហ្អី?

ផាន ៖ បាទ!

ឈុនលី ៖ បឋមសិក្សា?

ផាន ៖ ស្រែះលិច ។

ឈុនលី ៖ ពូឈ្មោះអីចេះពូ?

ផាន ៖ ណៃ ផាន ។

ឈុនលី ៖ ណៃ ផាន?

ផាន ៖ បាទ!

ឈុនលី ៖ ពូធ្វើនាយកសាលាយូរប្ហុនៅ?

ផាន ៖ ខ្ញុំធ្វើនាយរងនោះចាប់ពី៩៦ មកដល់២០០៨ មកដល់២០០៨ បានឡើងនាយក ។ ខ្ញុំធ្វើគ្រូតាំងពី៨៣ ។ ថាមិនចង់ធ្វើដែរទេ តែដល់តែពេលថាវាមានការឈឺចាប់ពីនោះមក វានឹកឃើញការឈឺចាប់វាចេះតែចង់ឲ្យបងប្អូនធ្វើការទាំងអស់ ។

ឈុនលី ៖ អីចឹងពេលចេញពីខ្មែរក្រហមមកបង្រៀនធ្វើគ្រូធម្មតាសិនប្ហុយ៉ាងម៉េចបានឡើងដល់នាយក?

ផាន ៖ ពីដើមខ្ញុំគ្រូបន្ទុកថ្នាក់ដែរ ខ្ញុំចេញពី៨៣មកខ្ញុំគ្រូបន្ទុកថ្នាក់ ។

ឈុនលី ៖ នៅសាលាណា?

ផាន ៖ សាលា មុនដំបូងនៅសាលាអីលិចណោះ ហ្អួស!មុនដំបូងនៅពាមកម្ម ដកចេញពីពាមកម្មមកនៅស្រែះលិច ដកពីស្រែះលិចទៅស្រែះកើត ដកពីស្រែះកើតទៅនៅស្រែះលិចវិញ គេផ្លាស់ឲ្យទៅនៅកន្លែងវិញ ។

ឈុនលី ៖ ចុះដល់ពេលពូឡើងធ្វើនាយកនៅស្រែះលិចហ្នឹងនៅឆ្នាំណា?

ផាន ៖ ឆ្នាំ២០០៨ ។

ឈុនលី ៖ ហើយសិស្សសាលាក្នុងថ្នាក់ខស្សាហ៍និយាយរឿងរ៉ាវមកប្រាប់ទេ?

ផាន ៖ និយាយ គ្រូខ្ញុំមានពីរដែលគាត់ចាស់ៗណាស ខ្ញុំមួយនាយករងខ្ញុំមួយគាត់ប៉ិននិយាយណាស់គ្រូហ្នឹងពីសាវតា ។

ឈុនលី ៖ លោកគ្រូនាយករងហ្នឹងគាត់ធ្លាប់ទៅធ្វើការនៅនោះត្រពាំងថ្មដែរអត់?

ផាន ៖ អត់ទេ គាត់អ្នកបាត់ដំបង ដល់បាត់ដំបងមកគាត់សម័យរបបអន្តរណែងចាន់បានប្រពន្ធ នៅនេះឯង ។ គាត់ប្រសព្វណាស់ គាត់និយាយណែនាំក្មេង និយាយពីរឿងរ៉ាវរបបខ្មែរ ក្រហមម៉េចៗគាត់ប្រសព្វ គាត់ប៉ិននិយាយ ។

ឈុនលី ៖ ចុះពេលពូនិយាយប្រាប់ក្មេងអត់ជឿទេ?

ផាន ៖ បាទ!ក្មេងវាថាមិនមែនទេលោកគ្រូគ្មានអ្នកណាវៃមនុស្សចោល ដែលវាមិនទាន់ណាសវា អត់ជឿយើងទេ តែបើក្មេងម៉ាជំនាន់មុនដូចកាលខ្ញុំបង្រៀនពីដើមថ្នាក់ទីប្រាំ ថ្នាក់ទីប្រាំ ប្រលងចូលថ្នាក់ទី៦ កាលនោះយើងមានសៀវភៅបនប្រល័យពូជសាសន៍យ៉ាង ម៉េចៗ យើងឲ្យវាមើលទៅ ។

ឈុនលី ៖ កាលនោះមានដែរ?

ផាន ៖ កាលយើងសម័យរដ្ឋកម្ពុជាមាន សៀវភៅថ្នាក់ទី៥ ទី៦មាន ។ កាលខ្ញុំទៅបង្រៀននៅ ទានកម្មបង្រៀនៗខ្មែរក្រហមមកឈរពីមុខថ្នាក់ ភ័យ ក្មេងៗភ័យមុខឡើងខ្មៅគ្រប់គ្នា ។ រៀនៗទៅយើងអត់បានចាប់អារម្មណ៍ថាខ្មែរក្រហមហ្នឹងវាមកទេ វានៅទានកម្មហ្នឹងជិត ព្រៃចេញចូលៗ ។ កំពុងតែរៀនៗមិនបានមើលអាមុខទ្វារហ្នឹងមើលតែមុខក្មេងទេ កូន ក្មេងហ្នឹងមុខឡើងខ្មៅៗ ហើយវាមើលមកយើងដល់តែបែរមកវាកាន់អាដៃវានៅមាត់ទ្វារ ហើយវាសើចដាក់ ហើយវាថាលោកគ្រូបង្រៀនៗទៅ កន្លែងណាត្រូវដេរៗទៅ កន្លែង ណាមិនត្រូវដេរកុំដេរ តែថ្ងៃក្រោយសុទ្ធតែឲ្យកូនក្មេងយាម ។

ឈុនលី ៖ ពេលនិយាយហ្នឹងសុទ្ធតែឲ្យអ្នកយាមទៀត?

ផាន ៖ បាទ!សុទ្ធតែឲ្យកូនក្មេងដាក់វេនគ្នាយាមដូចថាទៅមើលនៅក្នុងព្រៃបើថាមានខ្មែរក្រហម ចេញពីស្វាយសរមកហ្នឹងឲ្យអាម្នាក់ហ្នឹងមកប្រាប់ មានអាអោមឥវ៉ាន់រត់ក៏មានដែរ ។

ឈុនលី ៖ ខ្លាច?

ផាន ៖ ខ្លាច ។

ឈុនលី ៖ ចុះអ្នកនេះហ្នឹងទាហានហ្នឹមកឈរមើលហ្នឹង?

ផាន ៖ ខ្មែរក្រហម ។

ឈុនលី ៖ ចាស ទាហានប្អូក៏ម៉េចស្លៀកពាក់?

ផាន ៖ ស្លៀកពាក់ទ័ពម៉ង ពណ៌ខៀវ ។

ប៊ុនម៉ា ៖ ពណ៌ស្វិកឈើ ។

ឈុនលី ៖ ចុះម៉េចក៏ពូចេះខ្លាចទៀតចឹង?

ផាន ៖ មិនខ្វាចយ៉ាងម៉េចបើក្រោយមកទៀតគេថាមិនមែនត្រឹមតែ...គេថាគ្រូ មេភូមិ មេក្រុម គេចាប់យកទៅរៀនសូត្រ ដល់យើងនៅកន្លែងប្រទាញប្រទង់ទាហានវាមិនដឹងថាទាហាន ទៅដល់ពេលណាព្រោះដីនោះជួនកាលទាហានចូលជួនកាលខ្មែរក្រហមចូល ។

ឈុនលី ៖ អាហ្នឹងនៅឯណា?

ផាន ៖ អាហ្នឹងនៅទានកម្ម ហើយខ្ញុំមកនៅនេះហើយក៏ខ្ញុំមិនដែលហ៊ានដេកផ្ទះ ។

ឈុនលី ៖ អាហ្នឹងនៅឃុំណា?

ផាន ៖ ឃុំទានកម្ម ស្រុកព្រះនេត្រព្រះ ។

ឈុនលី ៖ ទានកម្មយ៉ាងម៉េច?

ផាន ៖ ឃុំទានកម្ម ។

ឈុនលី ៖ ទានកម្ម?

ផាន ៖ បាទ! ចេញអាផ្លូវទានកម្មទៅៗអាងត្រពាំងថ្ម ។

ឈុនលី ៖ ហើយកាលនោះពូនិយាយដល់កន្លែងណាបានគេមកឈរមើល?

ផាន ៖ អាសៀវភៅថ្នាក់ទីពីរទីបីហ្នឹងមានហើយរបបប្រល័យពូជសាសន៍ដែលវាសំលាប់មនុស្ស ម៉េចៗនោះណាស តែសៀវភៅចាស់ហ្នឹងវាផុតអស់ទៅដល់ក្រោយមកទៀតបានគេដូរសៀវភៅថ្មីម៉ាសារទៀត ។

ឈុនលី ៖ ហើយមានទៀត?

ផាន ៖ អត់ទេដល់ពេលអាយើង៩៣ អីនេះមកវាអស់ហើយ បើអាកាលសម័យយើងរដ្ឋកម្ពុជា យើងដំបូងគឺមានសៀវភៅនោះទាំងអស់ ហើយវាៗចូលទៅមើលវាមើលយើងគូសរូបវាយ សំលាប់ប្រជាជនចឹងទៅណាស វ៉ៃប្រជាជន ចងប្រជាជន កាប់សម្លាប់អីចឹងទៅ ហើយវាថាកន្លែងណាលោកគ្រូត្រូវនិយាយ កន្លែងណាមិនត្រូវនិយាយមិនបាច់និយាយទេ ។ ហើយក្រោយមកទៀតវាហៅយើងទៅប្រជុំតាំងពីព្រឹករហូតដល់ម៉ោងបី ។

ឈុនលី ៖ ហៅគ្រូៗទាំងអស់?

ផាន ៖ បាទ! គេប្រជុំនៅវត្តនេះ ។

ឈុនលី ៖ វត្តអីគេ?

ផាន ៖ វត្តនៅទានកម្មនេះ មានតាស៊ូ តាជល សុទ្ធតែមេៗ គាត់ពីដើមគាត់សាស្រ្តចារ្យនៅថ្មគោល គ្រូណាស ។ គាត់ជិះឡានទៅម៉ាឡានគាត់ដាក់ដៃកៀនទាំយ៉ាងម៉េច អាឡានហ្នឹងបើកទៅដាច់ដៃ គាត់ក៏និយាយ ។ អាយើងសម័យខ្ញុំបង្រៀនហ្នឹង យើងមិននៅទ្រឹស្ដីមួយ

ថា រូបលេនីន រូបកាលម៉ាក យើងមិនដាក់ហ្អស ចឹងទៅពួកទាហានគេទៅសរសេរនៅអាចេតីហ្នឹងថា ជ័យយោសាមគ្គីវៀតណាមម៉ឺនឆ្នាំ វាសួរថាស្អីម៉ឺនឆ្នាំហ្នឹងលោកគ្រូជួយពិចារណាខ្ញុំស្អីម៉ឺនឆ្នាំហ្នឹង ។ ហើយខ្ញុំថាយើងដាក់តាំងរូប លេនីន រូបកាលម៉ាក អីទៅវាថាយើងនេះតាំងអីរូបគេ ម៉េចមិនតាំងរូបអ្នកស្នេហាជាតិយើង ។

ឈុនលី : គេចង់សំដៅលើអ្នកណាអ្នកស្នេហាជាតិហ្នឹង?

ផាន : អ្នកស្នេហាជាតិគេចង់សំដៅលើអាចារ្យស្វា អាចារ្យពោកំបោរ ហែមជាវ ហេតុអីក៏យើងទៅយករូប លេនីន កាលម៉ាកមកដាក់តាំងមកអី ចេះតែនិយាយទៅណាស ។ មានអីវានិយាយតែវាទៅ អត់បាយ ថ្ងៃក្រោយឡើងអត់មានតែមក...(ស្តាប់អត់បាន) ។

ឈុនលី : ចុះប្រជុំហ្នឹងនិយាយអីគេខ្លះ?

ផាន : និយាយពីរឿងនយោបាយខាងវាដូចថាបំពាក់បំប៉ននយោបាយអាយើងនយោបាយវាណាស ។

ឈុនលី : និយាយាថាម៉េចខ្លះទៅពូ?

ផាន : វាថាអីណោហសុទ្ធតែពួកខ្មាំងយួនខ្មាំងអីចឹងទៅណាស វាថាអីណោះខ្មាំងយួនហើយវាអ្នកស្នេហាជាតិអីទៅណាស ។ ដូចខ្ញុំធ្លាប់ឆ្លងកាត់មិនទៅជឿអី ធ្លាប់ហែលឆ្អែតអស់ហើយអាលំបាកយ៉ាងណាអីយ៉ាងណី ។

ប៊ុនម៉ា មិនមែនសម័យអាពតទេ ចប់សម័យអាពតហើយខ្មែរក្រហមនៅទានកម្មទៀត ធ្វើគ្រូហើយក៏នៅទានកម ទាហានខ្មែរក្រហមនៅហ្នឹងទៀត ។

ឈុនលី : នៅចល័យហ្នឹងមិនដែលនឹកនាថាឃ្លានបាយទេដូចថាយើង ចុះប្រើតាំងពីម៉ោង៦ព្រឹករហូតដល់ម៉ោង៩យប់ ។ ថ្ងៃត្រង់ម៉ោង១១មកស៊ីបាយអត់ឲ្យ គេមិនដេញយើងមែនប៉ុន្តែយើងអត់រួចឲ្យវា មានខ្លះដល់ម៉ោង៩យប់ ខ្លះដល់ម៉ោង១១យប់ទាល់តែរួច ។ ខ្ញុំនឹកឃើញស្រណោះពួកចល័តដែលមកជាមួយគ្នាជាពិសេសមកពីខាងកំពង់ស្ពឺដែលមកចុះពីលើឡានមកអត់មានម៉ែឪ មកនៅជាមួយគ្នាទៅផងឹតមាន២០នាក់គឺគោងគ្នាទៅធ្វើការទាំងយប់ ហើយបើដីនេះ ក្លួយឯងបើបានឃើញបានដឹង ។ បើខាងលើជំរៅម៉ាម៉ែត្រស្រួលណាស់ តែធ្លាក់ដល់កន្លះម៉ែត្រក្រោមមិនបាច់កាប់ទេ ហើយស្នាទោស បាត់អីបាត់ចុះកុំឲ្យតែបាត់ចប តែបាត់ចបផាប់ហើយ ទៅយកចបដាក់នឹងមុខហើយដេកអោបហើយ អោបចបកើយបន្តិកុំឲ្យបាត់ ។

ប៊ុនម៉ា : ចបហ្នឹងអាយុជីវិតហើយ ។

ផាន ៖ ទៅកន្លែងណាៗ រែកតែបង្គីហើយនិងចប ។

ឈុនលី ៖ ចុះពូខ្ញុំសុំសួរបកទៅរឿង យាយថែម ។ ពូដែលឃើញ យាយថែមទេ?

ផាន ៖ យាយថែម ខ្មៅ ។

ឈុនលី ៖ ពូស្គាល់ដែរ?

ផាន ៖ យាយថែម ខ្មៅ មាឌធំដំបង ។

ឈុនលី ៖ ធំដំបងទេ មិនមែនមាឌល្អិតទេ?

ផាន ៖ អត់ទេ យាយថែមមាឌធំ ។

ឈុនលី ៖ មុខមាត់គាត់ម៉េចទៅ?

ផាន ៖ ទេ មុខគាត់កាច ។

ឈុនលី ៖ នៅក្នុងនេះមានរូប យាយថែម ណាសពូ មិនដឹងថាពូអាចចំណាំគាត់បានដែរអត់?

ផាន ៖ ហួស!មិនដែលបានឃើញទេ ។

ឈុនលី ៖ រូបនៅខាងក្រៀននេះពូ រូបហ្នឹងថតជាមួយនាយកខ្ញុំ កាលនោះគាត់ទៅព្រះវិហារ ។

ផាន ៖ ចាស់ហើយ កាលខ្ញុំឃើញនៅក្មេង ។

ឈុនលី ៖ អាចថាចំណាំមុខអីចឹងទេ?

ផាន ៖ បាទៗ!

ឈុនលី ៖ តែមាឌដំបងទេ?

ផាន ៖ បាទ! កាលគាត់នៅក្មេងគាត់ធាត់ ។

ឈុនលី ៖ គាត់មានប្តីទេតើហ្អី?

ផាន ៖ គាត់កាលនោះមាន តែមិនដឹងតាអីទេ ។

ប៊ុនម៉ា ៖ តែគេថាយាយថែមអត់មានប្តី?

ផាន ៖ បើពួកសហករណ៍នៅនេះ ពួកនារីខ្ញុំបានគាត់អត់ប្តី នារីខ្ញុំគ្រូ ប្រធានសហករណ៍ដែរ ។ សហករណ៍នេះតាយឿម កាលសម័យនរតីសម័យ...

ប៊ុនម៉ា ៖ តាចាប!

ផាន ៖ ទេ!តាចាប ហ្នឹងគេហៅកម្មាភិបាលភូមិ គាត់អ្នកក្តាប់ដូចថាម៉ាភូមិនេះក្តាប់លើក្រុម លើភូមិលើសហករណ៍គឺ តាចាប គាត់ក្តាប់ ។

ឈុនលី ៖ យាយថែម អ្នកតាកែវ ។

ប៊ុនម៉ា ៖ នាងបើភូមិយើងនេះ ក្រោបក្តាប់ភូមិយើងនេះក្តាប់បានទាំងអស់ ដល់តែសុទ្ធតែមកពីខាងណោះ អ្នកថ្មីទាំងអស់ ។

ឈុនលី ៖ ចឹង យាយថែម នៅចាំទាំងអស់ដល់ចប់?

ផាន ៖ កាន់រហូតដល់ពេលយើងចូលមក ។

ឈុនលី ៖ ដល់ពេលវៀតណាមចូល យាយថែម រត់ដែរ?

ផាន ៖ បាទ!ចេញ ។

ឈុនលី ៖ រត់ទៅខាងណា?

ផាន ៖ ទៅខាងភ្នំឆ័ត្រ ។

ឈុនលី ៖ ឥឡូវគាត់នៅខាងអន្លង់វែង ។

ផាន ៖ បាទ!គាត់នៅខាងភ្នំឆ័ត្រ ។

ឈុនលី ៖ ចឹងពូដឹងថាគាត់គណៈស្រុក យាយថែម?

ផាន ៖ បាទ! គណៈស្រុក យាយថែម ។

ឈុនលី ៖ ចឹងបាននត្រពាំងថ្មហ្នឹងគេធ្វើមុនពេល យាយថែម មកទៀត?

ផាន ៖ បាទ!

ឈុនលី ៖ យាយថែម ហ្នឹងមកគាត់គ្រប់គ្រងបន្តពីគេ?

ផាន ៖ បាទ!បន្ត ។

ឈុនលី ៖ ហើយមីងត្រពាំងថ្មហ្នឹងធ្វើរយៈពេលប៉ុន្មានទៅបានហើយ?

ប៊ុនម៉ា ៖ ត្រពាំងថ្មរយៈពេល៨ ៩ខែទៅដឹងនាង ។

ឈុនលី ៖ យូរម្ល៉េះមីង?

ប៊ុនម៉ា ៖ មីងទៅហ្នឹងឆាប់បានត្រលប់មកវិញដែរ ។

ឈុនលី ៖ មីងទៅហ្នឹងម៉ាខែត្រឡប់មកវិញ?

ប៊ុនម៉ា ៖ មិនបានម៉ាខែពេញទេ បើមីងចាន់ទី និងមីងគឹមលាង គេទៅបានយូរជាងខ្ញុំ ។

ឈុនលី ៖ មីងគឹមលាង ហៅវ៉ាន ហ្នឹងហ្អី?

ប៊ុនម៉ា ៖ ហ្នឹងឯង ។

ឈុនលី ៖ ម្សិលមិញខ្ញុំជួបគាត់ ។

ប៊ុនម៉ា ៖ នោះឯងឃើញអត្តុយទីនោះ គេទៅបានយូរជាងខ្ញុំ ។

ឈុនលី ៖ គាត់ថាទៅបានបីខែ ។

ប៊ុនម៉ា ៖ នោះឯងទៅបានយូរដាងខ្ញុំ ។

ឈុនលី ៖ គាត់ថាហូបបាយនៅនោះ តែដល់មីងហូបបបរ?

ប៊ុនម៉ា ៖ ហូបបបរ ។

ឈុនលី ៖ ម៉េចខុសគ្នាចឹងហ្ន៎?

ប៊ុនម៉ា ៖ វាចែកផ្នែកគ្នា ។

ឈុនលី ៖ អ្នកលើកម៉ាម៉ែត្រផ្សេង ពីរម៉ែត្រផ្សេង បីម៉ែត្រហ្នឹងឲ្យហូបផ្សេងចឹងហ្អី?

ប៊ុនម៉ា ៖ ចាស ។

ផាន ៖ អានេះបើនិយាយទៅគ្រួសារខ្ញុំជាប់ប្រវត្តិ ។

ប៊ុនម៉ា ៖ ពុកខ្ញុំធ្វើប្រធានភូមិពីសង្គម ។

ឈុនលី ៖ ហ្អស!ភូមិអី?

ប៊ុនម៉ា ៖ ប្រធានភូមិនៅភូមិស្រែះនេះឯង ប្រធានភូមិចាស់ចឹងឯង ។

ឈុនលី ៖ ហើយក្នុងសម័យខ្មែរក្រហមហ្នឹងគេចាប់គាត់ដែរ?

ប៊ុនម៉ា ៖ ចាប់ គេចាប់គាត់ទៅឃុំនៅឯក្រោមឡើងម៉ាអាទិត្យ ។

ឈុនលី ៖ ក្រោមណាទៅ?

ប៊ុនម៉ា ៖ ទៅអីចែកអន្តរអីបាក់ព្រា ព្រៃគ្រប់យើងនោះណាស ។

ឈុនលី ៖ បាក់ព្រា?

ប៊ុនម៉ា ៖ នោះឯងទៅកន្លែងធំវា ។

ឈុនលី ៖ ស្រុកណា?

ប៊ុនម៉ា ៖ ស្រុកអី ស្រុកបាត់ដំបងហ្អីឪវា ស្រុកបាត់ដំបង ។ ដល់ពេលជាប់ប្រវត្តិក៏ខ្លាចគេទាំងម៉ែទាំងកូនទាំងឪមិនដែលហ៊ានសួរនាំអីគេទេ ។

ឈុនលី ៖ ហើយចឹងយើងគេអត់ចាប់ខ្លួនដែរ?

ប៊ុនម៉ា ៖ អត់ចាប់ទេ គេចាប់គាត់ទៅសួររឿងនយោបាយខាងទាហ៊ាន លន់ នល់ ម៉ាអាទិត្យលែងមកវិញ ។

ឈុនលី ៖ ហ្អស!បាត់គាត់?

ប៊ុនម៉ា ៖ នោះឯង ។

ឈុនលី ៖ ចុះម្ដាយអត់អី?

ប៊ុនម៉ា ៖ អត់អី ។

ឈុនលី ៖ ហើយកូនចៅអត់អីដែរ?

ប៊ុនម៉ា ៖ អត់ ដូចថាគេដឹងថាប្រវត្តិពុកខ្ញុំមនុស្សល្អ ស្លូតត្រង់ណាស ទៅគេអត់ធ្វើបាប ។

ឈុនលី ៖ ចុះបងប្អូនមីងផ្សេងៗទៀតទៅធ្វើការនៅឯណា?

ប៊ុនម៉ា ៖ ផ្សេងៗទៀតនោះមានធ្វើពេទ្យម្នាក់?

ឈុនលី ៖ កាលលើកមុននោះ?

ប៊ុនម៉ា ៖ កាលសម័យបីឆ្នាំនោះ?

ឈុនលី ៖ ចាស!

ប៊ុនម៉ា ៖ អត់មានអ្នកណាធ្វើអីទេ គេជំរុះចោលទាំងអស់អត់មានអ្នកណាធ្វើអីទេ ។

ឈុនលី ៖ តែមានតែមីងទេទៅធ្វើការនៅទំនប់?

ប៊ុនម៉ា ៖ នោះឯង បងទីមួយទីពីរគាត់មានប្ដី ដល់ពេលត្រឹមខ្ញុំមកអត់មាន អត់ទាន់មានបានគេជម្លៀសឲ្យចេញ ។

ឈុនលី ៖ ចុះប្អូនៗតូចៗ?

ប៊ុនម៉ា ៖ ប្អូនៗតូចៗ ។

ឈុនលី ៖ នៅកងកុមារ?

ប៊ុនម៉ា ៖ នោះឯង បើមីប្អូនមួយដែលនៅភ្នំលាភនោះ គេទើបតែឲ្យទៅអាចុងក្រោយគេឆេះ ងាប់អស់មិនចេះតិច ។

ឈុនលី ៖ ភ្លើងឆេះហ្នឹងឆេះរឿងអី?

ប៊ុនម៉ា ៖ ខ្មែរក្រហមដុត ដុតរោងដុតអីដែលយើងទៅលើកណាស ។

ឈុនលី ៖ ទំនប់ត្រពាំងថ្មហ្នឹង?

ប៊ុនម៉ា ៖ នោះឯងទំនប់ត្រាពាំងថ្ម ចុងបង្ហើយ ។

ឈុនលី ៖ ចុះម៉េចបានខ្មែរក្រហមដុត?

ប៊ុនម៉ា ៖ ដុតកុំឲ្យយើងធ្វើ អានោះយួនចូលអុកឡុកហើយណាស អុកឡុកគ្នាហើយ ទៅហ្នឹងគេថាយើងចូលដៃចូលជើងយួនទៅវាដេញ ងាប់អស់ល្ហូចល្ហេវ ។

ឈុនលី ៖ ងាប់ដោយសារដុតហ្នឹង?

ប៊ុនម៉ា ៖ ងាប់ដោយសារដុត ត្រូវគ្រាប់តគ្នា បាញ់គ្នាខ្លះឆេះសំពត់ ឆេះអាវ ។

ឈុនលី ៖ អាហ្នឹងពេលវៀតណាមចូលមក?

ប៊ុនម៉ា ៖ វៀតណាមចូលមកហើយ ។

ឈុនលី ៖ ហើយយើងអត់ទាន់ធ្វើទំនប់ទេ ។

ផាន ៖ យើងនៅដូចថា អាកាលសម័យករប្រាំគេហៅ ម្ហូល ។

ឈុនលី ៖ ឆ្នាំណាហើយ?

ភាន ៖ អាឆ្នាំយើង៧៩ ៧៨ ហួស!៧៩ ៨០នេះហើយ គេហៅទៅជួសជុល គេហៅវិះសេនាជនហ្នឹងណាស ទៅជួសជុល ។ ខ្មែរក្រហមនៅម្ខាង ហើយទាហានវានៅហ្នឹងដែរ វាចូលមកវាអត់បាននេះអី វាបាញ់នៅនឹងកន្លែងនោះ ហើយទាហានមានបានគអីវាចេញទៅបាត់ ។ ងាប់ម៉ាផ្ទះបីនាក់នៅប៉ោយសំរោង នៅភូមិប៉ោយសំរោង ។ ទៅលើកទាំងអស់ពួកចល័តក្មេងៗឲ្យនៅកុមារនៅត្រឹមនេះ យុវជននារី ។ ប្អូនថ្លៃខ្ញុំទៅអាសម័យពេលវៀតណាមចូលមកហើយទៅជួយថែទំនប់សារថ្មីវិញណាស ដល់ពេលនេះទៅខ្មែរក្រហមគេមកបាញ់ បាញ់នៅកន្លែងទំនប់ បាញ់ដុតរោងដុតអីឆេះ រត់ខ្វះឆេះខោអាវឆេះអីនៅសល់តែខ្លួនទទេ ស្ទាទោស!ខ្លួនឆេះរោល...។ នៅតំបន់នេះយើងសន្តិភាពមែនប៉ុន្តែទាល់តែ៩៣ ហើយទេបានឈប់ ។

ឈុនលី ៖ ចឹងអាកាល៨១ ៨២?

ផាន ៖ អាហ្នឹងកាន់តែខ្លាំងហើយ ទាំងគេទាំងខ្ញុំអត់ហ៊ានដេកផ្ទះទេ ។

ឈុនលី ៖ មានវៀតណាមនៅហ្នឹងទៀត?

ផាន ៖ វៀតណាមមាន តែវៀតណាមនៅតែទីរួមស្រុក នៅតាម...មកសុំអង្ករសុំអីទាំងថ្ងៃទៅណាស ។

ឈុនលី ៖ មកដល់ភូមិនេះដែរ?

ផាន ៖ បាទ មកដល់ភូមិនេះ មកនៅតាំងពីព្រឹកចឹងរហូតដល់យប់បានវាចេញ ។

ឈុនលី ៖ យប់ឡើងចូលព្រៃវិញ?

ផាន ៖ បាទ!យប់ឡើងចូលព្រៃ ថ្ងៃឡើងជួនកាលវានៅតាមវាលទៅ យប់ល្ងាចបន្តិចចូលមកហើយពួកខ្ញុំមិនហ៊ាននៅទេ អ្នកធ្វើការមេភូមិមេក្រុមរត់ទាំងអស់អត់មានអ្នកណាហ៊ានដេកទេខ្លាចវាចាប់ ។

ឈុនលី ៖ ហើយចឹងពួសូវតែបាញ់គ្នាចឹងទៅ?

ផាន ៖ បាទ! បាញ់គ្នាឡើងនេះ ទើបតែមក៩៣នេះទេដែលយើងបានស្រួល ។ ៩៣ បោះឆ្នោតហើយក៏វានៅឆ្ងាយៗណាស ។

ឈុនលី ៖ ទាហានអស់ហ្នឹងគ្រប់គ្រងដោយអ្នកណាគេ?

ផាន ៖ ទាហានខ្មែរក្រហមនៅព្រៃខាងក្រោម សព្វថ្ងៃក្រុមគាត់នៅឧត្តមានជ័យ នៅសំរោង ។ ពួក តាស៊ូ ពួកតាថែម តាវ៉ោយ តាហ៊ាវ អីណាពួកគាត់ក្រុមគាត់តែសព្វថ្ងៃគាត់ចូលសមាហរណកម្មអស់ហើយ ។ ថ្ងៃឡើងគាត់មក ។

ឈុនលី ៖ ហ្នឹងគ្រប់គ្រងដោយ អៀង សារី ហ្អី?

ផាន ៖ បាទ?

ឈុនលី ៖ អ្នកណាគ្រប់គ្រងនៅហ្នឹងមេធំ?

ផាន ៖ បាទ! មេធំកាលគាត់គ្រប់គ្រងនៅនេះ អ៊ី ឈាន តាអ៊ី ឈាន អភិបាលខេត្តប៉ៃលិន ។

ឈុនលី ៖ អ៊ី ឈាន ឬសុខ ភាព?

ផាន ៖ អ៊ី ឈាន ។

ឈុនលី ៖ អ៊ី ឈាន ខាងប៉ៃលិនហ្អី?

ផាន ៖ បាទ!

ឈុនលី ៖ ហើយ សុខ ភាពខាងម៉ាឡៃ?

ផាន ៖ បាទ!

ឈុនលី ៖ តែខ្ញុំអត់ដឹងថានៅនេះអ្នកណាគេទេ ។

ផាន ៖ គាត់ហ្នឹងម៉ាក្រុមគាត់ខាងនេះឯងមេអគ្គ...កន្លែងគាត់ធំនៅអីនោះ តែសាខាគាត់...ពួកគាត់នេះប្រចាំមុខសញ្ញាខាងទន្លេសាប តែខែវស្សាចុះទៅនៅអីក្រោម ខែប្រាំងខែវស្សាទៅនៅអីក្រោម តាមពិតគាត់នៅនោះនៅតាម...ដែរ ។ ហើយដួនកាលអាពេលបើកអន្លុរបើកអីគាត់មិននៅភ្នំឆ័ត្រ ពួកគាត់ម៉ាខ្សែៗទៅនៅភ្នំឆ័ត្រតែពួកគាត់នេះ...បែកកំលាំងគ្នាណាស ។ ពួកនេះហើយច្រើនតែមកអុកឡុកនៅតាមភូមិ ។

ឈុនលី ៖ ចុះពេល៧៩ ពេលវៀតណាមចូលកមកពួនៅឯណាហើយ?

ផាន ៖ នេះនៅនេះដែរ ។

ឈុនលី ៖ ហើយម៉េចទៅក្នុងភូមិ?

ផាន ៖ ក្នុងពេល៧៩ហ្នឹងដូចខ្ញុំថាអត់ហ៊ានដេកទេ ។

ឈុនលី ៖ នៅតែចលាចល?

ផាន ៖ បាទ! នៅចលាចលដូចថាយប់ឡើងវាចូលមក វាចូលមកដូចខ្ញុំថាវាចូលមកដើម្បីវាហៅឲ្យយើងយកទឹមរទេះគោទៅជាមួយវា ពួកវារកច្រកចេញទៅនោះអត់រួច យកប្រជាជនទៅ ។

ឈុនលី ៖ ទៅបន្ទិចៗជាមួយវា?

ផាន ៖ បាទ!បន្ទិចៗជាមួយយើងទៅ ទំរាំតែបានចេញប្រហែលជាកន្លះខែអីណោះ ។ វា ថ្ងៃឡើង ចឹងអត់ឃើញ យប់ឡើងមកដល់ តែមកដល់ដើរប្រកួកហៅឲ្យយើងរៀបចំគោរទេះ ។

ឈុនលី ៖ កាន់កាំភ្លើងកាន់អីមកហ្អី?

ផាន ៖ កាំភ្លើង ។

ឈុនលី ៖ ចុះទាហានយើងនៅអត់ដល់នេះទេ?

ផាន ៖ ទាហានយើងនៅស្រុក ។

ឈុនលី ៖ ហើយអត់មានអ្នកណាទៅប្រាប់ទេ?

ផាន ៖ ទៅប្រាប់ឯណា ថ្ងៃឡើងទាហានខ្លាចដែរ កាលនោះទាហានស្រុកយើងមកអត់ទាន់បាន ដែរអាកាលយើង៧៩ហើយនោះណាស ៧៩ហើយបានវៀតណាមអីនៅ ។ វានោះ វៀតណាមបើកតាមផ្លូវនោះ យើងនេះកំពុងតែប្រទាញប្រទង់ហើយ ថ្ងៃឡើងស្ងាត់យប់ ឡើងមក ។ យប់ឡើងនាំគ្នាទៅដេកនៅសាលាឃុំ ។

ប៊ុនម៉ា ៖ ល្ងាចឡើងហូបបាយពីនេះទៅហើយ ។

ឈុនលី ៖ អ្នកភូមិនេះទៅទាំងអស់?

ប៊ុនម៉ា ៖ ទៅទាំងអស់អត់មានសល់ទេ ។

ផាន ៖ ជួនកាលនៅសល់តែប្រុសៗទេ ។

ឈុនលី ៖ ឡើងមករកអីស៊ី?

ប៊ុនម៉ា ៖ ហ្នឹងឯងឡើងមករកអីស៊ីហើយសំលាប់ ។

ឈុនលី ៖ មានសម្លាប់ទៀត?

ប៊ុនម៉ា ៖ មាន ។

ឈុនលី ៖ អ្នកស្រុកនេះមានអ្នកស្លាប់ទៀត?

ផាន ៖ បាទ!ស្លាប់មកដល់បាញ់ ។

ប៊ុនម៉ា ៖ អត់មានទេ ប៉ុន្តែដូចថាវាមានបាតុភាពមកណាស ។

ឈុនលី ៖ ស្រុនេះមានដែរអត់? ភូមិនេះ?

ផាន ៖ ទេ ភូមិនេះអត់ទាន់មានស្លាប់ទេ ។

ឈុនលី ៖ ធ្លាប់ឮហ្អី?

ផាន ៖ ធ្លាប់ពុកវាគំរាមយើងនោះណាស ម្ហោះហើយចេះតែខ្លាច ល្ងាចឡើងដឹកកូនទៅ ស្មើនេះអីទៅអស់ហើយស្ងាត់ជ្រាប ។

ឈុនលី ៖ ហើយចឹងអ្នកស្រុករកស៊ីអីចោះ?

ផាន ៖ រកស៊ីអី ថ្ងៃឡើងថាត្រៀមតែហូបបាយទៅដឹកកូនដឹកចៅទៅ ។

ឈុនលី ៖ ធ្វើស្រែដែរអត់?

ផាន ៖ ធ្វើស្រែ ម៉ោងបីឡើងដឹងតែដាំបាយហើយ ដុះខ្ញុំតែដល់ម៉ោងបួនម៉ោងប្រាំរត់អត់បាយហើយអត់នៅផ្ទះទេ ។

ឈុនលី ៖ ចឹងពូនៅបង្រៀនទៀតដែរ?

ផាន ៖ នៅបង្រៀនថ្ងៃឡើង យប់ឡើងរត់ដេកតាមព្រៃ ។

ឈុនលី ៖ ហើយចឹងប្រាក់ខែបើកពីខាងណាវិញ?

ផាន ៖ កន្លែងអប់រំស្រុក នៅជប់ ។

ឈុនលី ៖ តំបន់ប្រទាញប្រទង់ហ្នឹង?

ផាន ៖ បាទ!

ឈុនលី ៖ កាលនោះបានប៉ុន្មាន?ដូរស្រូវទេដឹង បើកជាប្រាក់ឬក៏ដូរស្រូវ?

ផាន ៖ ពីដំបូងប្រាក់យើងនេះគេអត់បើកឲ្យយើងទេ គេគិតជាអង្ករ គិតជាប្រេងកាត គិតជាសាប៊ូគិតជាអីក្រណាត់ចឹងទៅណាស តែបានតែរបបអង្ករទៅយកលុយទៅទិញអង្ករប្រេងកាត សាប៊ូគេឲ្យរបប ស្កសរចឹងទៅណាស ។

ឈុនលី ៖ ចុះពូក្រោយមកដែលដឹងរឿងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមទេ?

ផាន ៖ ដឹងដែរដឹងតែគេកាត់ទោស០០១នោះណាស ។

ឈុនលី ៖ តាឌុច!

ផាន ៖ បាទ!តាឌុច តាមសាលាខ្ញុំគេឲ្យសៀវភៅខ្លះអាសៀវភៅខ្មៅៗ ។

ឈុនលី ៖ ប្រវត្តិសាស្ត្រខ្មែរក្រហមហ្នឹងហ្នឹពូ?

ផាន ៖ បាទ!

ឈុនលី ៖ ចែកបានច្រើនទេ?

ផាន ៖ បាទ!ចែកគ្រូៗបានម្នាក់ម៉ាក្បាលៗ ។

ឈុនលី ៖ ខាងណាចែកឲ្យ?

ផាន ៖ ខាងអង្គការមួយគេយកមកឲ្យខាងអប់រំស្រុក ។

ឈុនលី ៖ អន្ដការខ្ញុំហ្នឹងឯង!

ផាន ៖ បាទ!ដល់អប់រំស្រុកចែកមកតាមសាលា ។

ឈុនលី ៖ បានច្រើនក្បាលទេ?

ផាន ៖ បាទ!បានច្រើន គ្រូម្នាក់ម៉ាក្បាល ៦នាក់ហ្នឹង បើខ្ញុំនេះគេឲ្យខ្លួនឯងម៉ាក្បាល ទីចាត់ការម៉ាក្បាលបានពីរក្បាល ។

ឈុនលី ៖ ហ្នឹងហើយអន្ដការពួកខ្ញុំចែក ចឹងទើបតែបានសៀវភៅហ្នឹងដែរ?

ផាន ៖ បាទ!

ឈុនលី ៖ ចឹងដឹងតាមរយៈហ្នឹង?

ផាន ៖ តាមទូរទស្សន៍ ។

ឈុនលី ៖ ចុះពូមានដឹងរឿង០០២ទេ?

ផាន ៖ ដូចជាអត់ទាន់បានដឹងទេ ។

ឈុនលី ៖ ពូមានដឹងទេអ្នកណាខ្លះនៅក្នុងរឿង០០២ក្រៅពីតា ឌុច?

ផាន ៖ អត់ដឹងទេ ។

ឈុនលី ៖ មាន នួន ជា អៀង សារី ខៀវ សំផន អៀង ធិរិទ្ធ បួននាក់ ហើយចុងខែ៦ថ្ងៃទី២៧ ២៨ហ្នឹងគេមានសវនាបឋម គេពិភាក្សាគ្នាថាត្រូវធ្វើយ៉ាងម៉េចៗចឹងណាស ។ ហើយខែបន្ដៗទៀតគេនឹងបើកសវនាការដូច តាឌុច ហ្នឹងចឹង ហើយតា ឌុច ហ្នឹងពូដឹងទេថាកាលលើកមុនគេកាត់ទោសគាត់ប៉ុន្មានឆ្នាំ?

ផាន ៖ ទេ ខ្ញុំឮគេផ្សាយថា១៥ឆ្នាំ ។

ឈុនលី ៖ ៣៥ឆ្នាំ ។

ផាន ៖ ៣៥ឆ្នាំ ។

ឈុនលី ៖ ដល់ពេលក្រោយមកគេកាត់កុះដោយសារកាលឆ្នាំ១៩៩៩ ពេលគេចាប់ខ្លួនគាត់ឃុំនៅតុលាការយោធាលើសច្បាប់កំណត់ ឃុំខ្លួនគាត់ខុសច្បាប់ណាសបើនិយាយទៅឡើង៩ឆ្នាំ ដល់ពេលចឹងគេកាត់បន្ថយដោយសារគាត់សហការជាមួយតុលាការ គាត់និយាយរឿងច្រើនចឹងណាស ចឹងទៅគេកាត់បន្ថយនៅសល់១៩ឆ្នាំ ។ ប៉ុណ្ណឹងហើយគាត់នៅមិនព្រមទៀត គាត់ប្ដឹងបន្ដទៅទៀត ហើយខាងព្រះរាជអាជ្ញាហ្នឹងក៏អត់ព្រមដែរ ។ ពីដំបូងព្រះរាជអាជ្ញាស្នើដាក់ទោស៤០ឆ្នាំ តែតុលាការសំរេចឲ្យ៣៥ ដល់ពេលកាត់កុះទៅនៅសល់ ១៩ឆ្នាំ ហើយព្រះរាជអាជ្ញាក៏អត់ព្រម ។ ហើយអ្នកដែលដាក់ពាក្យបណ្ដឹង ជនរងគ្រោះ

ដែលគាត់ដាក់ពាក្យបណ្ដឹងទៅតុលាការខ្មែរក្រហមក៏គាត់អត់ព្រមដែរ គាត់ប្ដឹងដែរគាត់ប្ដឹងទៅថ្នាក់លើ ហើយតា ឌុចខ្លួនឯងហ្នឹងក៏គាត់អត់ព្រមដែរ គាត់ប្ដឹងដែរ។ តាឌុច សុំរួចខ្លួន ខែកប៉ុន្មានទេ...ខែបីអីចេះមិនដឹងទេ គាត់ឡើងប្ដឹងគេហៅថាប្ដឹងទៅតុលាការកំពូលណាស ហើយសេចក្ដីសំរេចអត់ទាន់ចេញទេ អាចថាចេញនៅខែ៦ ឬខែ៧ដែរ។ អីចឹងចាប់ពីខែនេះទៅតុលាការរវល់អារឿងហ្នឹង។

ដាន : បាទ!ខ្ញុំមើលអាប៉ុស្ដិបាយ័នគេសួរថាតើ...គោលបំណងខ្ញុំក៏ចង់សួរអីចឹងដែរ សួរថាតើតាឌុច គាត់ជាប់គុកនៅព្រៃសរ តើគាត់ កន្លែងគាត់ដេកដូចអ្នកទោសធម្មតាឬមួយគាត់មានកន្លែងដេកស្នាក់អីស្រួលបួល? បើតាមចិត្តខ្ញុំ ខ្ញុំថា...នៅសាលាខ្ញុំមានសៀវភៅមួយរបស់អគ្គការ អែហ្វ ប៊ី អេ ហៅអគ្គការស៊្ហានោះណាស គេបើកឲ្យនោះគេដាក់ថាបងធំទី១ ប៉ុល ពត ដល់មើលបងធំទី១ ប៉ុល ពត គឺអ្នកចេះដឹងច្រើន គាត់សំលាប់ច្រើនណាស់និយាយរួមទៅសុទ្ធតែដៃស្ដាំរបស់គាត់ខ្ញុំមិនបានចាំឈ្មោះទេ គិតទៅគាត់សំលាប់អ្នកចេះដឹងច្រើនណាស់ ចឹងបានខ្ញុំថាគួរតែដាក់គាត់ឲ្យយូរហើយឲ្យគាត់ដេកដូចយើងផងដេកកន្លែងធម្មតាកុំឲ្យពិបាកថា...អ្នកខ្លះគេថាឌុច ជាប់គុកមែនតែម៉ាស៊ីនត្រជាក់។ ខ្ញុំថាគំនិតខ្លួនខ្ញុំដែលបានគិតខ្លួនឯងថាសម័យប៉ុល ពត ប្រជាពលរដ្ឋឈឺចាប់ប៉ុណ្ណាគួរតែច្បាប់ដាក់គាត់យ៉ាងណាឲ្យសមនឹងការឈឺចាប់របស់ប្រជាពលរដ្ឋ។ ហើយដូចខ្ញុំអីចឹងបើយើងនិយាយឲ្យដល់ទៅបន្ទោសអាអ្នកក្រោម អាអ្នកក្រោមវាទទួលបញ្ជាពីថ្នាក់លើដល់ខ្ញុំមកគិតខ្លួនឯងខ្ញុំគិតថាខ្ញុំទៅរករឿងអាអ្នកចាប់ប្អូនខ្ញុំហ្នឹងវាមិនកើត ព្រោះគ្នាទទួលបញ្ជាពីថ្នាក់លើ ចឹងបានចាប់អ្នកធំៗបានមកគួរតែយើងធ្វើយ៉ាងម៉េចឲ្យសមនឹងការឈឺចាប់របស់ប្រជាពលរដ្ឋដែលអស់បងអស់ប្អូន។ បើអាប្អូនខ្ញុំមួយនោះនៅស្រុកសព្វថ្ងៃវាឈ្មោះអាសារីៗ ម៉ាគ្រួសាររលីងនៅសល់តែវាម្នាក់ទេ ឪពុកម្ដាយ ប្អូនវាអីអស់នៅសល់តែវាតែឯង។ ដល់នៅចឹងទៅខឹងចិត្តរត់ទៅធ្វើ ៧៩ ៨០ទៅធ្វើទាហានរហូតទើបតែឃើញចូលស្រុកប៉ុន្មានឆ្នាំនេះ ហើយខ្ញុំសួរថាស្លាប់កន្លែងណា ថាស្លាប់នៅអាម៉ាជួរបាត់ដំបងដែរនៅជួរភ្នំតាផ្ដេរដែរ តែខ្ញុំនឹកឃើញថាកាត់ទោសដាក់ឲ្យគាត់តែ ត្រឹមគាត់ស្នើសុំវា ប្រជាពលរដ្ឋយើងមិនពេញចិត្ត វាមិនស្មើហ្នឹងគាត់ដែលគាត់...ជាពិសេសនៅគុកទួលស្លែង អាស-២១ គេអ្នកធំៗអ្នកចេះអ្នកដឹងងាប់នៅនោះឯង។ ចឹងបានថ្ងៃមុនខ្ញុំប្រជុំអារឿងធ្វើទិវាកុមារអន្តរជាតិ១ មិថុនា បានសារសម្ដេចនាយកថាយើងមិនមែនធ្វើតែសំរាប់កុមារអន្តរជាតិទេសូម្បីតែកុមារកម្ពុជាយើងស្លាប់នៅក្នុងបីឆ្នាំ ៨ខែ ២០ថ្ងៃ

នេះក៏វេងគ្រោះធ្ងន់ធ្ងរណាស់ដែរ ។ បាននឹកឃើញថា ដាក់គាត់ឲ្យពេលនេះគាត់នៅមានរូបមានរាងមានត្រឹមតែដាប់គុក ហើយចុះប្រជាជនកញ្ញខ្មែរដែលគាត់សំលាប់មិនបានដួបអីសោះនោះត្រូវកាប់ត្រូវសម្លាប់ៗ ចឹងបានខ្ញុំស្ដាប់ប៉ុស្ដិមួយនៅប្រទេសឥណ្ឌូនេស៊ីគេធ្វើប្រជាពលរដ្ឋគេតវ៉ាដើម្បីឲ្យរដ្ឋាភិបាលធ្វើច្បាប់មួយអត្តឃាតសត្វ សំលាប់សត្វគោ ដល់កសិដ្ឋានគេសុំឲ្យរាជរដ្ឋាភិបាលធ្វើច្បាប់សម្លាប់សត្វគោកុំឲ្យទៅដល់បកស្បែកគ្នាទាំងរស់វេទនាណាស់ ។ ហើយរបីគិតមកអាគាត់មួយនៅត្រង់ណាទេថា ចំណែកឯស្រុកខ្មែរយើងវិញបើមានច្បាប់ដូចឥណ្ឌូនេស៊ី ប្រហែលជាស្រួលហើយវាក៏ចង់កើតទៅជាសត្វគោវិញព្រោះមានច្បាប់នៅឥណ្ឌូនេស៊ី នៃពិធីករគេថា កុំចង់កើតជាសត្វអីកើតជាមនុស្សទៅសព្វថ្ងៃគេមានច្បាប់ហើយ ។ កាលពីសម័យនោះវាអត់មានច្បាប់ ។ ខ្ញុំ ប្រវត្តិរូបលាក់រហូតខ្ញុំថា ខ្ញុំមិនដែលធ្វើអី មិនដែលបានរៀន មិនដែលបានបួសមិនដែលបានអីទាំងអស់លាក់រហូតប្រវត្តិរូបរហូតមកដល់សម័យវៀតណាមចូលមក៧៩នេះខ្ញុំក៏ដាក់ពាក្យគ្រូអាចារ្យមួយគាត់នៅនេះគាត់ធ្លាប់ជួបខ្ញុំនៅព្រៃវែង គាត់និយាយកាលពីសម័យបីឆ្នាំគាត់ទំនាក់ទំនងនិយាយជាមួយខ្ញុំ គាត់ហៅខ្ញុំឲ្យធ្វើគ្រូ អ្នកស្រុកគេថា ម៉ាអាមកពីស្រុកគេតាំងពីសម័យ ប៉ុល ពត មិនឃើញចេះអីម៉ាតួដងមកដាក់ពាក្យធ្វើគ្រូ ។ ចឹងកាលសម័យនោះយើងសំដែងពីប្រវត្តិរូបគឺងាប់ហើយ ដូចដាក់ប្រវត្តិរូបថានៅរៀននៅអីដឹងតែយកយើងទៅវៃចោលហើយ ចឹងមួយៗមកថាមិនចេះល្ងង់រហូត ឲ្យតែយើងអ្នកថ្មីគឺដឹងតែយើងលាក់រហូត សម័យនោះ ។ ហើយខ្ញុំសម័យនោះខ្ញុំមិនដែល សូម្បីតែសៀវភៅក៏ខ្ញុំមិនដែលមើលឲ្យគេឮ ខ្ញុំមិនដែលហ៊ាន ។ មកដល់ពោធិ៍សាត់ខ្ញុំក្រវែងចោលអស់សៀវភៅមិនដែលដាក់ក្នុងកាបូបទេ ។

ឈុនលី ៖ ពូដល់ពេលនិយាយរឿងគាដ្ឋចឹងខ្ញុំនឹកឃើញ កាលនោះគេជម្លៀសចេញទាំងអស់តែពូចេញមកនេះ?

ដាន ៖ បាទ!

ឈុនលី ៖ ចុះប្រជាជនដែលនៅកន្លែងគាដ្ឋហ្នឹងចេញទៅណាទៀត?

ដាន ៖ អ្នកខ្លះត្រលប់ទៅផ្ទះវិញ អ្នកខ្លះគឺស្លាប់ ។

ឈុនលី ៖ ចុះនៅគាដ្ឋហ្នឹងធ្វើអី មានគេនៅកន្លែងហ្នឹងទៀត? មានសហករណ៍នៅណុងទៀតហ្អី?

ដាន ៖ ពួកយើងអ្នកថ្មីទៅគេបង្កើតភូមិមួយដើម្បីយកយើងទៅដាក់នៅជើងភ្នំ ។

ឈុនលី ៖ គេឲ្យយើងធ្វើអី?

ផាន ៖ ឲ្យយើងធ្វើចំការធ្វើស្រែដាំអីធម្មតា គ្រាន់តែថាទៅ ឧទាហរណ៍ ខ្ញុំចេះទៅញពីរនាក់ប្ដីប្រពន្ធគេដកទៅធ្វើនៅចល័ត ហើយយើងនៅតែពីរនាក់ប្ដីប្រពន្ធ កូនចៅអត់ឲ្យនៅទេ ចឹងប្អូនខ្ញុំដែលថានៅភ្នំគាផ្ដហ្នឹងបងខ្ញុំអត់ទាន់ប្រាប់គេថាប្អូនមួយទេ ចឹងប្អូនខ្ញុំគេអត់ឲ្យនៅជាមួយឲ្យមកនៅចល័ត ហើយដល់ពេលបងខ្ញុំនេះ...ចុះបងស្រីខ្ញុំគាត់បាត់មុនគេមកតាំងពីសម័យឆ្នាំ៧០ បាត់បងស្រីមួយរហូតទើបតែចូលឆ្នាំកៅប៉ុន្មានទេបានគាត់ចូលមកវិញ។ អីចឹងការគ្រប់គ្រងបងប្អូនសុទ្ធតែប្រុស។ បងខ្ញុំមួយជួនកាល...បងខ្ញុំពីរនាក់បួសនៅខ្ញុំពីរនាក់ប្អូនស្រី ហ្វឺឪពុកខ្ញុំឈឺ។ ដល់ពុកខ្ញុំឈឺទំរាំតែគាត់យកប្រពន្ធមួយទៀត ខ្ញុំនៅពីរនាក់ប្អូនស្រី រៀនក៏ពីរនាក់ប្អូន ជិះកង់ទៅ មកវិញដាំបាយទៅសួរទៅ ពីរនាក់បងប្អូនបានបងខ្ញុំគាត់សឹកបួសមកទាំងអស់មកបានខ្ញុំនេះធូរ។ ពេលដែលគាត់មកពីបួសអស់មកបានប្រពន្ធគេទៅប្ដីប្រពន្ធគេទៅ ពេលហ្នឹងគេទៅគេហៅជីរំដោះឆ្នាំ៧៣

គេទៅជីរំដោះទៅខ្ញុំមិនព្រមទៅ បងគាត់ថា «ម៉េចឯងទៅជាមួយអញទេ?» ថាទេខ្ញុំមិនទៅទេ ម៉េចបានថាខ្ញុំមិនទៅ ខ្ញុំខ្លាច ម៉ាងៃ១យើងមិនដែលបានដេកស្រួល គិតតែដេកក្នុងត្រង់សេ ខ្លាចកប៉ាល់ហោះខ្ញុំនៅជាមួយម្ដាយមីងហ្នឹងរកស៊ីដើរកាប់ប្រអោងកាប់អីលក់ទៅ ។ ថ្ងៃមួយនោះគេចាប់ខ្ញុំធ្វើទាហាន។

ឈុនលី ៖ ឆ្នាំណាទៅ?

ផាន ៖ ឆ្នាំ៧៥ ចុងឆ្នាំ៧៤ ធ្វើទាហានចេញបានទៅចំការដូងប្រមូលកាំភ្លើងយកទៅឲ្យគេហើយប្រប៉ូកប្រប៉ល់មិនចេះចប់ហ្នឹងខ្ញុំនៅភ្នំពេញ។

ឈុនលី ៖ ចឹងកាលធ្វើទាហានហ្នឹងធ្វើនៅភ្នំពេញ?

ផាន ៖ បាទ!

ឈុនលី ៖ ទាហានខ្មែរទុកហាមឬទាហាន លន់ នល់?

ផាន ៖ ទាហាន លន់ នល់ គេចាប់។

ឈុនលី ៖ ដល់ពេលខ្មែរក្រហមចូលយើងរត់គេចតែម្ដង?

ផាន ៖ បាទ! ខ្មែរក្រហមចូលឈប់នៅភនំពេញ ដូចថាគេឲ្យចេញណាស ឲ្យយើងចេញហ្នឹងគេថាឲ្យចេញមកលេច ខ្ញុំក៏នាំគ្នាចេញចមកលេច។ ចេញមកហ្នឹងអត់មានបងប្អូនជួបទាំងអស់ទៅជួបម្ដាយមីងនៅស្រុក។ ទៅជួបម្ដាយមីងនៅស្រុកទៅនៅ១ទៅដល់ពេលដែលគេដេញអ្នកជីរំដោះអ្នកមូលដ្ឋានគេណាស បានម្ដាយចុងខ្ញុំហ្នឹងគាត់មក។ គាត់ទៅលេកីនេះ

គាត់ទៅតាមកូនគាត់ កូនគាត់បង្កើតណាស ។ ដល់ទៅជួបជុំគ្នាទៅគេចាប់បែងចែកហើយ ខ្ញុំប្រជាជន១៧ ម្ដាយខ្ញុំប្រជាជន១៨ ។

ឈុនលី : ១៨ ចេញមកក្រោយម៉ាងែ?

ផាន : ទេ ១៨មិនា ។

ឈុនលី : ១៨មិនា មុនពេលខ្មែរក្រហមចូលទៀត?

ផាន : បាទ!សម័យយើងទំលាក់សម្ដេចសីហនុ ។

ឈុនលី : ហ្អស!តាំងពី៧០នោះ?

ផាន : បាទ!អាហ្នឹងគេចាប់ណាស គេចាប់មួយប្រជាជន១៧ មួយប្រជាជន១៨ ហើយខ្ញុំនេះ ប្រជាជន១៧មេសា ម្ដាយចុងខ្ញុំប្រជាជន១៨មិនា ។ នៅៗទៅ គេមេឃុំគេចុះទៅដូចថា យើងយុវជនចឹងគេឲ្យយើងដកសំណាបទៅ ស្ទូងអីទៅ មេភូមិគេដើរឆ្វែលហើយថា អង្គរ អាដើមតាមដើម កញ្ចុំតាបមកញ្ចុំ ព្រោះគេប្រុងចំរាញ់យើងដើម្បីបញ្ជូនយើងមក ណាស ចឹងទៅថ្ងៃមួយគេហៅខ្ញុំទៅ គេហៅទៅខ្ញុំកំពុងដកគេហៅទៅថា “មិត្តឯងត្រូវទៅ បាត់ដំបងហើយ” ខ្ញុំថាម៉េចបានត្រូវទៅបាត់ដំបង? គេថា “មិត្តឯងធ្វើទាហានចំមុខ ដល់នេះខ្ញុំថានៅនឹងមុខអាឆ្នុំថា “ធម្មតាឆ្នុំឯងមិនដែលមានអ្នកណាធ្វើទាហានមិនចំមុខទេ ឥឡូវទទាហារណ៍ ខ្ញុំកាន់កាំភ្លើង ខ្ញុំសុខចិត្តឲ្យគេបាញ់ខ្ញុំសម្លាប់ឬខ្ញុំបាញ់គេវិញ? ខ្ញុំការ ពារជីវិតខ្ញុំ គេការពារជីវិតគេដូចតែគ្នាហ្នឹង” បានវាថា “អត់ទេ!មិត្តឯងត្រូវទៅ” ខ្ញុំថា “អត់អីទេខ្ញុំទៅបាន”...។

ឈុនលី : ឆ្នុំហ្នឹងកាចទេ?

ផាន : ទេ!កាលសម័យនោះកាចមែនណាស យើងមិនហ៊ានមើលមុខគេ គេមិនឲ្យមើលមុខគេទេ ហើយមនុស្សមិនមែនថា នៅស្រុកឆ្ងាយអី ស្រុកជាមួយគ្នា ។ កាលនៅតូចៗគេមិនទាន់ បានធ្វើការធ្វើអីយើងអាចថាឃ្វាលគោឃ្វាលអីជាមួយគ្នាទៅណាស ដល់មកសម័យនេះ គេបានធ្វើធំគេអត់ស្គាល់យើងណាស គេដាក់បញ្ជាមកថា មិត្តឯងត្រូវតែទៅចេះៗទៅ ។ ខ្ញុំមិននិយាយរៀបចំឥវ៉ាន់អីមក ឲឹងតែត្រង់ថាវានិយាយថា “ឥឡូវបើមឹងឯងហ៊ានធានា មឹងឯងហ៊ានសម្លាប់ខ្លួនឯងទេ?”ខ្ញុំនឹកឃើញឆ្អែត ។

ឈុនលី : អីចឹងម្ដាយចងពូចិត្តបានណាសហ្ន៎?

ផាន : បាទ!ចិត្តបាន ខ្ញុំសរសើគាត់ បងប្អូនខ្ញុំទាំងអស់ ខ្ញុំសរសើរគាត់ ។ កូនគាត់ឪពុកគាត់ គាត់អត់នៅជាមួយទេសុខចិត្តមកនៅជាមួយបងប្អូនខ្ញុំ ។

ឈុនលី ៖ អីចឹងដោយសារតែគាត់ដើររកពូបានគាត់ស្លាប់?

ផាន ៖ បាទ!នៅគាផ្ដេ តែគ្រាន់តែថាបងខ្ញុំមិនបង្កើតមិនដឹងថាម្ដាយចុងខ្ញុំស្លាប់ឬមួយក៏យ៉ាងណា ។

ឈុនលី ៖ អត់ទាន់ដឹងច្បាស់ទេ?

ផាន ៖ បាទ!អត់ទាន់ដឹងច្បាស់ទេ ហើយប្អូនខ្ញុំទៀតក៏ដូចគ្នាតែគាត់រំពឹងខ្លួនគាត់ថា គាត់មិនរស់ទេ គាត់ថាមិនរស់ទេ ហើយពួដំណឹងថាខ្ញុំនៅនេះ គាត់ប្រុងតែមកចេះដើរនិយាយទៅគេចាប់អារម្មណ៍គេហៅទៅ ប៉ុន្តែបងខ្ញុំគាត់ថាស្មានតែគាត់ស្លាប់ ។

ឈុនលី ៖ ចុះឥឡូវដូចមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមធំៗអីចឹងពូនៅខឹង ពូធុំ ហើយមីងម្នាក់ទៀតឈ្មោះអី?

ផាន ៖ ឈ្មោះ សាង ។

ឈុនលី ៖ សាង ពូនៅខឹងទៀតដែរ?

ផាន ៖ ទេ!ដលនេះទៅនៅតែខឹងដែរហ្នឹង តែគ្រាន់តែនឹកឃើញថា មិនបានគិតពីសន្ដានចិត្តយើងផងនៅតែខឹងដែរ ។ បងប្អូនភូមិ ស្រុកជាមួយគ្នាហើយគួរតែយើងអនុគ្រោះឬមួយក៏យើងគិតថាកាលពីដើមឡើយកាលពីយើងសម័យមុនភូមិ ស្រុកនៅជិតគ្នាយើងមិនតែងតែប្រាស្រ័យទាក់ទងគ្នាដូចខ្ញុំពុកខ្ញុំក្ដី ខ្ញុំពុកវាក្ដីតែងតែទំនាក់ទំនងគ្នាទៅវិញទៅមកបើភូមិនៅជិតគ្នា ហើយគួរតែគិតថាអ្នកស្រុកភូមិឯងយើងគួរតែជួយធ្វើម៉េចខុសត្រូវយ៉ាងណាយើងជួយកែតំរូវគ្នាណាស ដល់ពេលសម័យនោះមកយើងកាន់ច្បាប់មក ខ្ញុំទៅសួរថា “ខ្ញុំមិនដឹងទេ កាលនោះក្រោមមេឃតែងតែត្រូវទឹកភ្លៀង” បើលោកឯងនិយាយអីចឹងវាដូចតែខ្ញុំចឹង នៅសម័យ លន់ នល់ ក៏ចឹងដែរនៅក្រោមមេឃតែងតែត្រូវទឹកភ្លៀងដូចគ្នា តែអត់និយាយនឹងខ្ញុំ ។

ឈុនលី ៖ អត់និយាយជាមួយគ្នា?

ផាន ៖ បាទ!

ឈុនលី ៖ ពូអត់ដែលទៅលេងនៅនោះទៀតទេ?

ផាន ៖ ទៅ!ខ្ញុំទៅកាលខែមុនដែរ ។

ឈុនលី ៖ អត់រវីរវល់ទេ?

ផាន ៖ បាទ!វានឹកឃើញថាឆ្អែតដែរ ។

ឈុនលី ៖ គាត់នោះអត់ដែរ?

ផាន ៖ បាទ! ព្រោះក្រុមគ្រួសារគេនៅ ដល់ក្រុមគ្រួសារយើងទៅទៀតវាដូចថាធំៗ ទៅតាមខ្សែ ណាស ដល់គ្រួសាយើងទៅវាមិននិយាយ,

ឈុនលី ៖ ចុះពូការជាមួយមីងឆ្នាំណា?

ផាន ៖ ឆ្នាំ៧៧ ។

ឈុនលី ៖ ៧៧?

ផាន ៖ បាទ!

ឈុនលី ៖ មីងដល់ពេលការហើយគេឈប់ឲ្យទៅត្រពាំងថ្ម?

ផាន ៖ ឈប់ហើយ ។

ឈុនលី ៖ នៅធ្វើការនៅក្នុងភូមិវិញ?

ប៊ុនម៉ា ៖ គេឲ្យយើងដាំដំឡូងកិនស្រូវកិនអីទៅណាស ព្រោះយើងចូលវ័យកណ្ដាល ។

ឈុនលី ៖ អ្នកការហើយគេហៅថាវ័យកណ្ដាលហើយ?

ផាន ៖ បាទ!

ឈុនលី ៖ ហើយអាហ្នឹងគេចាត់ចូលក្រុមអី? ក្រុម គេហៅក្រុម?

ប៊ុនម៉ា ៖ ក្រុមវ័យកណ្ដាលហ្នឹងហើយ ។

ឈុនលី ៖ ហើយដល់ពេលការហើយគេឲ្យនៅរួមគ្នា?

ប៊ុនម៉ា ៖ នៅរួមគ្នាអត់ឲ្យទៅណាទៀតទេ ។

ឈុនលី ៖ នៅភូមិណាវិញ?

ប៊ុនម៉ា ៖ នៅភូមិយើងហ្នឹង?

ឈុនលី ៖ នៅផ្ទះហ្នឹង?

ប៊ុនម៉ា ៖ ទេ! នៅជាមួយម៉ែ មិនទាន់មានផ្ទះនៅទេ ។

ផាន ៖ កាលនោះបើសិនជាយើងអត់មានធ្វើអី ដូចថាមុខព្រួញ ដល់ខ្ញុំនេះខ្ញុំនៅឡើងត្នោត ដល់ខ្ញុំឡើងត្នោតទៅនេះបានគេឲ្យនៅ ។ បើយើងដូចថាយើងអត់មានការងារអីនៅនេះដឹងតែមុខព្រួញរាងខ្លួន ។

ប៊ុនម៉ា ៖ ប្ដីឡើងត្នោតយើងនៅដុតភ្លើងដុតអីទៅណាស ។

ឈុនលី ៖ ស្នើរឬគេរៀបចំឲ្យ?

ប៊ុនម៉ា ៖ នោះឯង ។

ឈុនលី ៖ គេរៀបចំឲ្យឬក៏យើងស្នើ?

ប៊ុនម៉ា ៖ គេរៀបចំឲ្យ ។

ផាន ៖ យើងស្នើទៅគេទៅ ។

ឈុនលី ៖ អ៊ីចឹងយើងស្នើហើយបានគេរៀបចំឲ្យ?

ផាន ៖ បាទ!

ឈុនលី ៖ ចឹងបានន័យថាយើងដឹងខ្លួនហើយមិនមែនចេះតែចាប់ដៃទេ ។

ផាន ៖ អានេះដូចថា ខ្ញុំហើយនេះអីចេះបានស្នើរ បើអ្នកខ្លះគេតំរូវ ។ ក្នុងថ្ងៃខ្ញុំនោះ៩០គូរ ។

ប៊ុនម៉ា ៖ បើកវគ្គ ។

ឈុនលី ៖ គេហៅបើកវគ្គ?

ប៊ុនម៉ា ៖ ចាប់ដៃគ្នានឹងវាល កណ្តាលវាលស្រែ ។

ឈុនលី ៖ មិនចាំបាច់ម៉ែឪណាដឹងឮទេ?

ផាន ៖ បាទ!៩០គូរ តែខ្ញុំក៏ដូចថាខ្ញុំវាមិន...ឪពុកខ្ញុំគាត់...តាមដានដឹងថាមនុស្សល្អចឹងពេលយើងបើកហើយយើងមិនមានសែនបាន រកមាន់រកអីសែន បើអ្នកខ្លះទៀតអត់ទេ ។

ឈុនលី ៖ ដល់ពេលចេញពីហ្នឹងមកនៅស្រុកភូមិពូនៅធ្វើការក្នុងភូមិ ពូទៅបង្រៀនដដែលចឹងទៅ?

ផាន ៖ បាទ!

ប៊ុនម៉ា ៖ ខ្ញុំតាំងពីបានប្តីមកមិនបានទៅណាទេ ។ ឈុនលី ៖

ឈុនលី ៖ នៅតែនឹងភូមិទេ?

ប៊ុនម៉ា ៖ នៅតែភូមិ ។

ឈុនលី ៖ ហើយឥឡូវបានកូនចៅប៉ុន្មានហើយ?

ប៊ុនម៉ា ៖ ៧នាក់ ។

ឈុនលី ៖ កូន៧?

ប៊ុនម៉ា ៖ ហ្នឹងឯង ប្រុសបួនស្រីបី ។

ឈុនលី ៖ ហើយកូនពៅនៅរៀនទេ?

ប៊ុនម៉ា ៖ មីស្រីមួយនោះទៅរកស៊ីស្រុកថៃទៅដេរជាមួយបង បងវាដេរដែរ ម៉ែអានេះដេរ ។

ឈុនលី ៖ ទៅថៃបានប៉ុន្មាននាក់?

ផាន ៖ តាមពិតតែពីរទេ តែទៅមានប្តីមានទប្រពន្ធគេ ។

ប៊ុនម៉ា ៖ ការអស់បួននាក់ ប្រុសពីរស្រីពីរ ។

ផាន ៖ យកកូនមកទុកនៅនេះតែមិនដឹងធ្វើម៉េច!

ឈុនលី ៖ បើចៅហើយ!

ផាន ៖ មានអីថែមទៀតទេពូ?

ឈុនលី ៖ បាទ!អត់មានទេ ។

ផាន ៖ អគុណហើយចឹងពូ ។

«ចប់»